# ក្របខ័ណ្ឌតាមដាន វាយតម្លៃ និងរៀនសូត្រ
# នៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# (២០២៤-២០២៨)

កំណែទី ០

សេចក្តីព្រាង

ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០២៤



## ព័ត៌មានឯកសារ

ត្រូវបានរៀបចំឡើងសម្រាប់៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
ឈ្មោះកម្មវិធី៖ កម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT)
កាលបរិច្ឆេទ ៖ ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០២៤

## ប្រវត្តិឯកសារ

| កំណែ | កាលបរិច្ឆេទចូលជាធរមាន | ការពណ៌នាអំពីការកែសម្រួល | រៀបចំឡើងដោយ | ពិនិត្យដោយ |
|---|---|---|---|---|
| ០ | ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០២៤ | សេចក្តីព្រាងសម្រាប់ពិភាក្សាក្នុងសិក្ខាសាលាខែ វិច្ឆិកា ឆ្នាំ ២០២៤ | Myra Navarro-Mukii (នាយកផ្នែកការតាមដាន វាយតម្លៃ និងរៀនសូត្រ, ASEAN-ACT) | |
| ១ | | | | |

# មាតិកា


**ពាក្យកាត់ និងអក្សរបំព្រួញ** **5**

**១ សេចក្ដីផ្ដើម និងសាវតារ** **6**

១.១ ទិដ្ឋភាពទូទៅនៃឯកសារនេះ 6

១.២ សាវតារ 7

១.៣ ទិដ្ឋភាពទូទៅនៃការតាមដាន និងវាយតម្លៃ 9

១.៤ តើក្របខ័ណ្ឌ MEL ត្រូវបានបង្កើតឡើងដោយរបៀបណា? 10

**២ ទ្រឹស្ដីនៃការផ្លាស់ប្ដូរ** **11**

**៣ ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌ MEL** **12**

៣.១ គោលបំណង និងវិសាលភាព 13

៣.២ គោលការណ៍ 14

៣.៣ អ្នកប្រើប្រាស់គោលដៅនៃក្របខ័ណ្ឌ MEL 14

៣.៤ ហានិភ័យ និងការសន្មត 15

**៤ វិធីសាស្ត្រតាមដាន និងវាយតម្លៃ** **16**

៤.១ សំណួរវាយតម្លៃសំខាន់ៗ 16

៤.២ អភិក្រមនៃការតាមដាន 18

៤.៣ វិធីសាស្ត្រតាមដាន 18

៤.៤ ការវាយតម្លៃ 19

៤.៥ ទិន្នន័យគោល និងការរំពឹងទុកលើសមិទ្ធកម្ម 19

**៥ ការរាយការណ៍ និងការរៀនសូត្រ** **21**

៥.១ ការរាយការណ៍ 21

៥.២ ការរៀនសូត្រ 21

៥.៣ ការអភិវឌ្ឍសមត្ថភាព MEL 22

**៦ សកម្មភាព MEL និងការទទួលខុសត្រូវ** **23**

៦.១ សកម្មភាព MEL 23

៦.២ តួនាទី និងការទទួលខុសត្រូវ 23

**៧ ក្រមសីលធម៌ក្នុងការតាមដាន និងវាយតម្លៃ** **24**

**ឧបសម្ព័ន្ធ ក ៖ ទ្រឹស្ដីនៃការផ្លាស់ប្ដូរ** **25**

**ឧបសម្ព័ន្ធ ខ ៖ សូចនាករដែលមានរៀបរាប់ក្នុងផែនការយុទ្ធសាស្ត្រជាតិ 26**
**ឧបសម្ព័ន្ធ គ ៖ វិធីសាស្ត្រ និងឧបករណ៍ប្រមូលទិន្នន័យ 34**
ឧបសម្ព័ន្ធរង គ.១៖ ការតាមដានសកម្មភាព 36
ឧបសម្ព័ន្ធរង គ.២៖ ព័ត៌មានលម្អិតអំពីអ្នកចូលរួម 37
ឧបសម្ព័ន្ធរង គ.៣៖ កម្រងសំណួរស្តីពីយោបល់ត្រឡប់ដែលបានស្នើឡើង 39
ឧបសម្ព័ន្ធរង គ.៤៖ ឧទាហរណ៍នៃស្វ័យវាយតម្លៃ និងការស្ទង់មតិក្រុមគោលដៅ 40
**ឧបសម្ព័ន្ធ ឃ ៖ គំរូរបាយការណ៍ 41**
**ឧបសម្ព័ន្ធ ង ៖ ម៉ាទ្រីសហានិភ័យ 42**
**ឧបសម្ព័ន្ធ ច ៖ សកម្មភាព MEL 43**
**ឧបសម្ព័ន្ធ ឆ ៖ ពាក្យគន្លឹះ និងនិយមន័យ 44**

## តារាង និងរូបភាព

តារាងទី ១ ៖ អ្នកប្រើប្រាស់ក្របខ័ណ្ឌ MEL 15
តារាងទី ២ ៖ សំណួរវាយតម្លៃសំខាន់ៗ សំណួរបន្ទាប់បន្សំ និងសូចនាករ 16
តារាងទី ៣ ៖ វិធីសាស្ត្រ និងឧបករណ៍ប្រមូលទិន្នន័យ 18
តារាងទី ៤ ៖ ការរំពឹងទុកលើសមិទ្ធកម្ម បែងចែកតាមសំណួរវាយតម្លៃសំខាន់ៗ 20
តារាងទី ៥ ៖ មាត្រដ្ឋាននៃការវាយតម្លៃដើម្បីវាយតម្លៃវឌ្ឍនភាពនៃលទ្ធផល និងការរំពឹងទុកលើសមិទ្ធកម្ម 20
តារាងទី ៦ ៖ សកម្មភាព ឬព្រឹត្តិការណ៍រៀនសូត្រសម្រាប់ការគ្រប់គ្រងបត់បែនតាមស្ថានភាព 22
តារាង ៧ ៖ ការទទួលខុសត្រូវក្នុងក្របខ័ណ្ឌ MEL 23

រូបភាពទី ១ ៖ យុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០២៤-២០២៨ 12

# ពាក្យកាត់ និងអក្សរបំព្រួញ

| | |
|---|---|
| ACTIP | អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CTIP | ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| EOSO | លទ្ធផលនៅចុងយុទ្ធសាស្ត្រ |
| GEDSI | សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម |
| M&E | ការតាមដាន និងវាយតម្លៃ |
| MEL | ការតាមដាន វាយតម្លៃ និងរៀនសូត្រ |
| M/PCCT | គណៈកម្មាធិការរាជធានី/ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| NCCT | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| SOMTC | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន |
| TIP | អំពើជួញដូរមនុស្ស |

## ១.សេចក្តីផ្តើម និងសាវតារ

ឯកសារនេះបង្ហាញពីក្របខ័ណ្ឌតាមដាន វាយតម្លៃ និងរៀនសូត្រ (MEL) សម្រាប់ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២៤-២០២៨ (ផែនការយុទ្ធសាស្ត្រជាតិ) របស់ព្រះរាជាណាចក្រកម្ពុជា។ ក្របខ័ណ្ឌ MEL ផ្តល់ជូនក្រសួង ស្ថាប័ន និងសមាជិកអង្គភាពឯកទេសនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងគណៈកម្មាធិការរាជធានី/ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ/ខ.ប.ជ) នៅថ្នាក់ក្រោមជាតិ និងដៃគូ នូវការរំពឹងទុក លទ្ធផលគោលការណ៍ និងការអនុវត្តពាក់ព័ន្ធនឹងការតាមដាន វាយតម្លៃ និងរាយការណ៍ ដែលរួមចំណែកដោយសកម្មភាពដែលបានគ្រោងទុក។ ឯកសារនេះបានពង្រីកប្រព័ន្ធតាមដាន និងវាយតម្លៃ (M&E) នៃផែនការយុទ្ធសាស្ត្រជាតិ (ផ្នែក ឃ) ដោយផ្តល់ព័ត៌មានលម្អិត និងការពណ៌នាបន្ថែមអំពីរបៀបអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃ (M&E)។

## ១.១ ទិដ្ឋភាពទូទៅនៃឯកសារនេះ

ក្របខ័ណ្ឌ MEL នេះចែកចេញជាផ្នែកដូចខាងក្រោម៖

- ផ្នែកទី ១៖ សេចក្តីផ្តើម និងសាវតារ
- ផ្នែកទី ២៖ ទ្រឹស្តីនៃការផ្លាស់ប្តូរ
- ផ្នែកទី ៣៖ ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌ MEL
- ផ្នែកទី ៤៖ វិធីសាស្ត្រតាមដាន និងវាយតម្លៃ
- ផ្នែកទី ៥៖ ការរាយការណ៍ និងការរៀនសូត្រ
- ផ្នែកទី ៦៖ សកម្មភាព MEL និងការទទួលខុសត្រូវ
- ផ្នែកទី ៧៖ ក្រមសីលធម៌ក្នុងការតាមដាន និងវាយតម្លៃ

ឯកសារនេះក៏មានឧបសម្ព័ន្ធផងដែរ៖

- ឧបសម្ព័ន្ធ ក៖ ទ្រឹស្តីនៃការផ្លាស់ប្តូរ
- ឧបសម្ព័ន្ធ ខ៖ សូចនាករដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រជាតិ
- ឧបសម្ព័ន្ធ គ៖ វិធីសាស្ត្រ និងឧបករណ៍ប្រមូលទិន្នន័យ
- ឧបសម្ព័ន្ធ ឃ៖ គំរូរបាយការណ៍
- ឧបសម្ព័ន្ធ ង៖ ម៉ាទ្រីសហានិភ័យ
- ឧបសម្ព័ន្ធ ច៖ សកម្មភាព MEL
- ឧបសម្ព័ន្ធ ឆ៖ ពាក្យគន្លឹះ

## ១.២ សាវតារ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) គឺជាយន្តការជាតិដែលមានភារកិច្ចដឹកនាំ សម្របសម្រួល ប្រមូលព័ត៌មាន វិភាគទិន្នន័យ រាយការណ៍វឌ្ឍនភាព និងផ្តួចផ្តើមកសាងច្បាប់ គោលនយោបាយ និងផែនការនានា ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលុបបំបាត់ការជួញដូរ និងការកេងប្រវ័ញ្ចមនុស្សគ្រប់ទម្រង់ ជាអាទិ៍មានការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការធ្វើអាជីវកម្ម និងកេងប្រវ័ញ្ចផ្លូវភេទ ការជួញដូរកុមារ/ទារក និងការជួញដូរសរីរាង្គមនុស្ស។ គ.ជ.ប.ជ ក៏ដឹកនាំការអនុវត្តដែលមានការចូលរួម និងសម្របសម្រួលអនុវត្តផែនការយុទ្ធសាស្ត្រជាតិដោយក្រសួង និងស្ថាប័នជាសមាជិកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត។

គ.ជ.ប.ជ ដឹកនាំ និងធ្វើជាប្រធានដោយឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានក្រសួងចំនួន ២២ និងអង្គភាពឯកទេសចំនួន ៥ ជាសមាជិក។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដឹកនាំដោយលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ។ អគ្គលេខាធិការដ្ឋាននេះដើរតួនាទីសំខាន់ក្នុងការសម្របសម្រួល ដឹកនាំ និងជំរុញកិច្ចសហប្រតិបត្តិការរវាងក្រសួង/ស្ថាប័ន និងដៃគូអន្តរជាតិ និងដៃគូក្នុងស្រុក ដោយផ្តោតសំខាន់លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

នៅចុងឆ្នាំ ២០២៣ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានដឹកនាំការវាយតម្លៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣ (ផ.យ.ជ)។ លទ្ធផល និងអនុសាសន៍នៃការវាយតម្លៃនេះបានផ្តល់មូលដ្ឋានព័ត៌មានដល់ការរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់ឆ្នាំ ២០២៤-២០២៨។

*គោលដៅ និងគោលបំណង ៖*

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២៤-២០២៨ មានគោលដៅលុបបំបាត់រាល់ទម្រង់ចាស់ថ្មីនៃអំពើជួញដូរមនុស្ស ដែលបង្កភាពរងគ្រោះដោយការធ្វើសកម្មភាពគ្រប់មធ្យោបាយ ក្នុងគោលបំណងកេងប្រវ័ញ្ចដោយទុចរិត ធ្វើឱ្យមនុស្សរងគ្រោះយ៉ាងធ្ងន់ធ្ងរដល់រូបកាយ សុខភាពផ្លូវចិត្ត ផ្លូវភេទ ដែលជាការរំលោភសិទ្ធិ អាយុជីវិត និងផលប្រយោជន៍ស្របច្បាប់របស់មនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ស្ថានភាព គ្រប់ពណ៌សម្បុរ ក្នុងដែនសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងលើប្រជាជនកម្ពុជានៅក្រៅប្រទេស។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨) លើកកម្ពស់សាមគ្គីភាព ឯកភាព និងកិច្ចសហការ ក្នុងភាពជាដៃគូរវាងសហគមន៍ជាតិ និងជាមួយអន្តរជាតិ ក្នុងគោលបំណងធានាឱ្យមានប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីការបង្ការទប់ស្កាត់ភាពរងគ្រោះឱ្យមានប្រសិទ្ធភាព ការ

អនុវត្តច្បាប់ដែលមានឥទ្ធិពល និងការផ្តន្ទាទោសយ៉ាងសុក្រឹតចំពោះបទឧក្រិដ្ឋនេះ ដើម្បីយុត្តិធម៌សង្គម ជាពិសេសការការពារសិទ្ធិផលប្រយោជន៍ស្របច្បាប់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាមនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ពណ៌សម្បុរ និងនៅគ្រប់ស្ថានភាព ក្នុងសង្គម។

ផែនការយុទ្ធសាស្ត្រជាតិនេះបានកំណត់យុទ្ធសាស្ត្រសំខាន់ៗ ៤ ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន និងឆ្លើយតបទៅនឹងដំណាក់កាលទាំង ៣ នៃបទល្មើសជួញដូរមនុស្ស៖ (១) ការបង្ការទប់ស្កាត់ (២) ការអនុវត្តច្បាប់ និង (៣) ការការពារ និងផ្តល់សេវាជូនជនរងគ្រោះ។ កិច្ចសហប្រតិបត្តិការគឺជាកត្តាជំរុញ និងជាគោលការណ៍មូលដ្ឋាននៃដំណាក់កាល/យុទ្ធសាស្ត្រទាំង ៣ នេះ។

- *យុទ្ធសាស្ត្រទី ១. ការបង្ការទប់ស្កាត់* - លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ។
- *យុទ្ធសាស្ត្រទី ២. ការអនុវត្តច្បាប់* - បង្កើនគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់។
- *យុទ្ធសាស្ត្រទី ៣. ការការពារ និងផ្តល់សេវាជូនជនរងគ្រោះ* - បង្កើនគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារជនរងគ្រោះ។
- *យុទ្ធសាស្ត្រទី ៤. កិច្ចសហប្រតិបត្តិការ* - ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្ត។

ក្របខ័ណ្ឌ MEL នេះរួមបញ្ចូលអនុសាសន៍ស្តីពីការតាមដាន វាយតម្លៃ និងរាយការណ៍នៃការវាយតម្លៃ ផ.យ.ជ ឆ្នាំ ២០២៣៖

- បន្តប្រើប្រាស់យន្តការ គ.ជ.ប.ជ ដែលមានស្រាប់នៅគ្រប់កម្រិត តាមរយៈការរាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។
- រៀបចំគោលការណ៍ណែនាំស្តីពីការតាមដាន វាយតម្លៃ និងរាយការណ៍ ដើម្បីណែនាំដល់មន្ត្រីថ្មីដែលត្រូវបានផ្ទេរឱ្យបំពេញតួនាទីរាយការណ៍អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- កែសម្រួល/ធ្វើបច្ចុប្បន្នភាពទម្រង់របាយការណ៍ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្របតាមសូចនាករដែលបានកំណត់ដែលអាចត្រូវបានប្រើប្រាស់ ដើម្បីវាស់វែងលទ្ធផលរំពឹងទុកពីការអនុវត្តសកម្មភាព ឬកម្រងសកម្មភាពក្នុងយុទ្ធសាស្ត្រនីមួយៗនៃផែនការយុទ្ធសាស្ត្រជាតិ។
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងបន្តសម្របសម្រួល និងតាមដានក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យពួកគេអាចចែករំលែកព័ត៌មាន ឬរាយការណ៍ទាន់ពេលវេលាអំពីសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលក្រសួង និងស្ថាប័នពាក់ព័ន្ធ បានអនុវត្ត។

- បង្កើនការផ្សព្វផ្សាយដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់អំពីសកម្មភាពដែលបានគ្រោងទុក និងអាទិភាពក្នុងផែនការយុទ្ធសាស្ត្រជាតិនាពេលអនាគត ដើម្បីឱ្យពួកគេអាចយល់បានកាន់តែច្បាស់ រៀបចំផែនការសកម្មភាព និងអាចអនុវត្តសកម្មភាពដែលបានគ្រោងទុកឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។
- គ.ជ.ប.ជ នឹងពិនិត្យលទ្ធភាពបង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យ ដើម្បីប្រមូលព័ត៌មានទាំងអស់ស្តីពីករណីជួញដូរមនុស្សក្នុងប្រទេស ដែលបន្សីគ្នានឹងមូលដ្ឋានទិន្នន័យជាតិផ្សេងទៀត និងទិន្នន័យដែលដៃគូកំពុងប្រើប្រាស់ ហើយក្នុងពេលជាមួយគ្នានោះ ធានារក្សាការសម្ងាត់ និងឯកជនភាពសម្រាប់បុគ្គលពាក់ព័ន្ធ។
- វាយតម្លៃយន្តការដែលមានស្រាប់នៅតាមក្រសួង និងស្ថាប័ននានាដើម្បីកំណត់រកវឌ្ឍនភាព បញ្ហាប្រឈម និងជំហានបន្ទាប់ ដើម្បីបង្កើតមជ្ឈមណ្ឌលទិន្នន័យ ក៏ដូចជាធានាសិទ្ធិឯកជនភាពរបស់ជនរងគ្រោះ។
- ពង្រឹងភាពទៀងទាត់នៃកិច្ចប្រជុំរបស់ក្រុមការងារនីមួយៗទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកែលម្អការទំនាក់ទំនង ការចែករំលែកព័ត៌មាន ការអនុវត្តល្អ មេរៀនដែលបានរៀនសូត្រ និងបទពិសោធន៍ជាក់ស្តែងលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ព្រមទាំងពិនិត្យឡើងវិញនូវសកម្មភាពដែលបានគ្រោងទុក បញ្ហាប្រឈមដែលពាក់ព័ន្ធ និងរបៀបឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនោះ។
- ចងក្រងជាឯកសារនូវការអនុវត្តល្អ រួមទាំងការសម្របសម្រួល កិច្ចសហប្រតិបត្តិការ ការប្រគល់សិទ្ធិអំណាច និងកិច្ចការពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការផ្តល់ជំនួយដល់ជនរងគ្រោះ ព្រមទាំងការគាំទ្រដល់ជនដែលធ្លាប់រងគ្រោះ (survivor) ដោយអំពើជួញដូរមនុស្ស ដើម្បីឱ្យពួកគេអាចមានឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ តាមរយៈសកម្មភាពរកប្រាក់ចំណូលដោយខ្លួនឯង។

## ១.៣ ទិដ្ឋភាពទូទៅនៃការតាមដាន និងវាយតម្លៃ

ការតាមដាន គឺជាដំណើរការនៃការប្រមូល និងពិនិត្យឡើងវិញជាទៀងទាត់ និងជាប្រព័ន្ធនូវទិន្នន័យដែលមានស្រាប់ ដែលផ្តល់ការបង្ហាញនៅពេលណាមួយអំពីវឌ្ឍនភាពឆ្ពោះទៅរកលទ្ធផលដែលបានគ្រោងទុក។ ការតាមដានត្រូវបានប្រើប្រាស់ជាញឹកញាប់នៅកម្រិតអង្គការផ្សេងៗ និងផ្តល់មូលដ្ឋានព័ត៌មានដល់ការគ្រប់គ្រងផ្ទៃក្នុង ការធ្វើសេចក្តីសម្រេច និងការកែលម្អជាបន្តបន្ទាប់។

ការវាយតម្លៃ គឺជាសកម្មភាពតាមកាលកំណត់ បានគ្រោងទុក និងមានគោលដៅ ដែលឆ្លើយតបនឹងសំណួរវាយតម្លៃសំខាន់ៗ និងពឹងផ្អែកលើទិន្នន័យថ្មី និងមានស្រាប់ ដែលភាគច្រើនត្រូវបានបង្កើតចេញពី

សកម្មភាពតាមដាន ដើម្បីធ្វើការវិនិច្ឆ័យ និងផ្តល់អនុសាសន៍។ ការវាយតម្លៃអាចជាការវាយតម្លៃផ្តោតលើដំណើរការ ឬអាចជាការវាយតម្លៃផ្តោតលើលទ្ធផល និងជួយផ្តល់ការយល់ដឹងកាន់តែស៊ីជម្រៅអំពីទិដ្ឋភាពសំខាន់ និងមានតម្លៃនៃអន្តរាគមន៍នានា ដូចជា ប្រសិទ្ធភាព ភាពសមស្រប ភាពពាក់ព័ន្ធ និរន្តរភាព និងផលប៉ះពាល់របស់វា។ ការវាយតម្លៃផ្តល់ការយល់ដឹងលើសពីសំណួរ 'អ្វី?' 'ដោយរបៀបណា?' និង 'ហេតុអ្វី?'។

ការតាមដាន និងវាយតម្លៃ គឺជាសកម្មភាព ឬអន្តរាគមន៍ដែលពាក់ព័ន្ធគ្នា ហើយនេះជាហេតុផលដែលការតាមដាន និងវាយតម្លៃត្រូវបានបញ្ចូលជាក្របខ័ណ្ឌរួមមួយ។ ជាញឹកញាប់ សូចនាករ និងទិន្នន័យតាមដាន បន្សុីគ្នានឹងសំណួរវាយតម្លៃ និងផ្តល់មូលដ្ឋានព័ត៌មានដល់លទ្ធផលរកឃើញពីការវាយតម្លៃ។ លទ្ធផលរកឃើញពីការវាយតម្លៃច្រើនតែផ្តល់មូលដ្ឋានព័ត៌មានដល់សកម្មភាពតាមដានដែលបានកែលម្អ និងមានលក្ខណៈលម្អិតជាងមុន។ រួមគ្នា ការតាមដាន និងវាយតម្លៃ ផ្តល់នូវមូលដ្ឋានភស្តុតាងដ៏សំខាន់ និងមានរចនាសម្ព័ន្ធ សម្រាប់ផ្តល់មូលដ្ឋានព័ត៌មានដល់ការធ្វើសេចក្តីសម្រេច គោលនយោបាយ យុទ្ធសាស្ត្រ និងការរៀនសូត្រ។

នៅក្នុងក្របខ័ណ្ឌ MEL នេះ ការតាមដានត្រូវបានស្នើឡើងនៅកម្រិតលទ្ធផលរំពឹងទុក និងកម្រិតលទ្ធផលរយៈពេលខ្លី។ ការវាយតម្លៃទំនងជាផ្តោតសំខាន់លើលទ្ធផលរយៈពេលមធ្យម និងរយៈពេលវែង ដើម្បីឆ្លើយតបនឹងសំណួរវាយតម្លៃសំខាន់ៗ (KEQ)។

## ១.៤ តើក្របខ័ណ្ឌ MEL ត្រូវបានបង្កើតឡើងដោយរបៀបណា?

រចនាសម្ព័ន្ធនៃក្របខ័ណ្ឌ MEL ផ្អែកតាមការវិភាគលម្អិតលើផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ ២០២៤-២០២៨ និងលទ្ធផលរកឃើញពីការវាយតម្លៃចុងក្រោយលើ ផ.យ.ជ ឆ្នាំ ២០១៩-២០២៣។ ក្នុងករណីដែលអាចធ្វើទៅបាន ធនធាន និងឯកសារបោះពុម្ពផ្សាយថ្នាក់ជាតិ និងតំបន់ដែលមានស្រាប់ បានផ្តល់មូលដ្ឋានព័ត៌មានដល់មាតិកា និងរចនាសម្ព័ន្ធនៃក្របខ័ណ្ឌ MEL ។. ធនធានពាក់ព័ន្ធពីកម្មវិធី ASEAN-ACT សៀវភៅណែនាំស្តីពីការតាមដាន និងវាយតម្លៃរបស់ ACWC BWP 2.0 និងសេចក្តីព្រាងក្របខ័ណ្ឌ MERL របស់ឯកសារនេះ។

សិក្ខាសាលាពិគ្រោះយោបល់លើកដំបូងជាមួយអ្នកពាក់ព័ន្ធត្រូវបានធ្វើឡើង នៅខែ វិច្ឆិកា ឆ្នាំ ២០២៤ រួមទាំងសមាជិក គ.ជ.ប.ជ។ ធាតុចូលពីអ្នកពាក់ព័ន្ធសំខាន់ៗលើសេចក្តីព្រាងក្របខ័ណ្ឌនេះត្រូវបានដាក់បញ្ចូលជាមូលដ្ឋានព័ត៌មានសម្រាប់ការកែសម្រួលសេចក្តីព្រាងក្របខ័ណ្ឌនេះ។ សេចក្តីព្រាងពេញលេញនៃក្របខ័ណ្ឌ MERL នឹងត្រូវបានបង្ហាញ និងលើកមកពិភាក្សាក្នុងអំឡុងសិក្ខាសាលាផ្ទៀងផ្ទាត់ដែលទំនងជាធ្វើឡើងនៅត្រីមាសទី ១ នៃឆ្នាំ ២០២៥។

## ២. ទ្រឹស្តីនៃការផ្លាស់ប្តូរ

រចនាសម្ព័ន្ធនៃក្របខ័ណ្ឌ MEL នេះប្រើប្រាស់ទ្រឹស្តីនៃការផ្លាស់ប្តូរ ឬម៉ូឌែលតក្កភាពដើម្បីពណ៌នាអំពីសកម្មភាព លទ្ធផលរំពឹងទុក លទ្ធផលរយៈពេលខ្លី លទ្ធផលរយៈពេលមធ្យម និងលទ្ធផលរយៈពេលវែងដែលបានដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ និងក្របខ័ណ្ឌតាមដាន និងវាយតម្លៃរបស់ ACWC។ ផ្នែកនេះបង្ហាញការពណ៌នាអំពីទ្រឹស្តីនៃការផ្លាស់ប្តូរ។ រូបភាពទី ១ តំណាងឱ្យយុទ្ធសាស្ត្រដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រជាតិ គឺដ្យាក្រាមពីផែនការនេះតែម្តង។

មានលទ្ធផលនៅចុងយុទ្ធសាស្ត្រ (EOSO) ចំនួន ៤ ដែលយើងរំពឹងថានឹងសម្រេចបាននៅចុងឆ្នាំ ២០២៨ ប្រសិនបើការសន្មតរបស់យើងគឺត្រឹមត្រូវ។

- លទ្ធផលទី ១ ៖ ក្រុមគោលដៅ ជាពិសេសក្រុមងាយរងគ្រោះ មិនសូវងាយរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់ទម្រង់។
- លទ្ធផលទី ២ ៖ ប្រព័ន្ធយុត្តិធម៌មានការឆ្លើយតបប្រកបដោយគុណភាព និងប្រសិទ្ធភាពទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់។
- លទ្ធផលទី ៣ ៖ ជនរងគ្រោះទទួលបានសេវាគាំទ្រប្រកបដោយគុណភាពនិងសមស្រប
- លទ្ធផលទី ៤ ៖ អ្នកពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបង្កើនកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ បង្ក្រាបបទល្មើស និងគាំទ្រជនរងគ្រោះ។

**តើអ្វីជាទ្រឹស្តីនៃការផ្លាស់ប្តូរ?**

ទ្រឹស្តីនៃការផ្លាស់ប្តូរគឺជាឧបករណ៍ត្រិះរិះដែលជួយឱ្យយើងយល់ និងបង្ហាញលទ្ធផលចុងក្រោយដែលយើងអាចរំពឹងទុកពីសកម្មភាពដែលបានអនុវត្តក្រោមផែនការយុទ្ធសាស្ត្រជាតិនេះ។

ទ្រឹស្តីនេះបង្ហាញពីទំនាក់ទំនង "ហេតុ និងផល" រវាងសកម្មភាព និងលទ្ធផលចុងក្រោយ។

ទ្រឹស្តីនេះក៏ជួយដល់យើងក្នុងការតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រជាតិផងដែរ ព្រោះយើងអាចផ្តោតសំខាន់លើការវាស់វែង និងការវាយតម្លៃថាតើមានការសម្រេចបានលទ្ធផលចុងក្រោយក្នុងកម្រិតណា។

[ត្រង់នេះ សូមបញ្ចូលការពណ៌នា ឬការរៀបរាប់អំពីលទ្ធផលចុងយុទ្ធសាស្ត្រនីមួយៗ ពីផែនការយុទ្ធសាស្ត្រជាតិ]

រូបភាពទី ១ ៖ យុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០២៤-២០២៨




## ៣.ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌ MEL

ក្របខ័ណ្ឌ MEL នេះប្រើប្រាស់ម៉ូឌែលតក្កភាព ឬលំដាប់លំដោយព័ត៌មានដែលភ្ជាប់គ្នាពីធាតុចូលទៅសកម្មភាព លទ្ធផលរំពឹងទុក និងលទ្ធផលរយៈពេលខ្លី និងលទ្ធផលរយៈពេលមធ្យម។ ក្របខ័ណ្ឌនេះគូសបញ្ជាក់ពីអ្វីដែលយើងនឹងតាមដាន និងវាយតម្លៃ ក្រោមផែនការយុទ្ធសាស្ត្រជាតិ ព្រមទាំងរបៀបដែលយើងនឹងប្រមូល និងវិភាគព័ត៌មាន ធ្វើការវិនិច្ឆ័យវាយតម្លៃ រាយការណ៍ និងកែលម្អយុទ្ធសាស្ត្ររបស់យើងក្នុងការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស។

**សកម្មភាព** នៅក្នុងក្របខ័ណ្ឌ MEL ត្រូវបានតម្រឹមតម្រង់មួយកម្រងសកម្មភាពដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រជាតិ ដែលត្រូវបានបង្ហាញនៅកម្រិតខ្ពស់ ក្រោមយុទ្ធសាស្ត្រទាំង ៤។ សកម្មភាពគឺជាវិធានការដែលបានធ្វើឡើង ឬការងារដែលបានបំពេញ ដែលតាមរយៈនោះ មានការកៀរគរធាតុចូល ដូចជា មូលនិធិ ជំនួយបច្ចេកទេស និងប្រភេទធនធានផ្សេងទៀត ដើម្បីផលិតលទ្ធផលជាក់លាក់។

**លទ្ធផលរំពឹងទុក** គឺជាផលិតផលរូបវន្ត ទំនិញ និងសេវាកម្មដែលផ្តល់ដោយសកម្មភាពដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រជាតិ។ ទាំងនេះជាលទ្ធផលដោយផ្ទាល់នៃសកម្មភាពនានា។ លទ្ធផលរំពឹងទុកដែលមានរៀបរាប់ក្នុងក្របខ័ណ្ឌ MEL រួមបញ្ចូលសូចនាករអាទិភាពដែលបានមកពីផែនការយុទ្ធសាស្ត្រជាតិ។ សូចនាករលទ្ធផលរំពឹងទុក មានរៀបរាប់ក្នុងឧបសម្ព័ន្ធ។

**លទ្ធផលរយៈពេលខ្លី** ផ្តល់ការពណ៌នាអំពីសមិទ្ធផលអាទិភាព ក្នុងរយៈពេល ២ ឆ្នាំ។ លទ្ធផលរយៈពេលខ្លីនៅក្នុងក្របខ័ណ្ឌ MEL គឺជាផលជះរយៈពេលខ្លីនៃកម្រងលទ្ធផលរំពឹងទុក លើយុទ្ធសាស្ត្រណាមួយនៃ យុទ្ធសាស្ត្រទាំង ៤។

**លទ្ធផលរយៈពេលមធ្យម** ផ្តល់ការពណ៌នាអំពីសមិទ្ធផលកម្រិតខ្ពស់ជាអាទិភាព ក្នុងរយៈពេល ២ ទៅ ៥ ឆ្នាំ។ លទ្ធផលរយៈពេលមធ្យមនៅក្នុងក្របខ័ណ្ឌ MEL ត្រូវបានចាត់ប្រភេទក្រោមលទ្ធផលនៅចុងយុទ្ធសាស្ត្រនីមួយៗក្នុងចំណោមលទ្ធផលទាំង ៤។ ទាំងនេះជាបុរេលក្ខខណ្ឌចាំបាច់ដើម្បីសម្រេចបានលទ្ធផលនៅចុងយុទ្ធសាស្ត្រ ឬលទ្ធផលរយៈពេលវែងដែលត្រូវបានកែសម្រួលពីផែនការយុទ្ធសាស្ត្រជាតិ។

**លទ្ធផលនៅចុងយុទ្ធសាស្ត្រ** គឺជាលទ្ធផលចុងក្រោយនៃផែនការយុទ្ធសាស្ត្រជាតិ ដែលគួរតែសម្រេចបាននៅឆ្នាំ ២០២៨ ប្រសិនបើការសន្មតគឺត្រឹមត្រូវ។

## ៣.១ គោលបំណង និងវិសាលភាព

ក្របខ័ណ្ឌ MEL នេះមានគោលបំណងសំខាន់ៗ ៤៖

- ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ទិសដៅយុទ្ធសាស្ត្ររបស់ គ.ជ.ប.ជ និងទីភ្នាក់ងារជាសមាជិករបស់ខ្លួនដោយផ្អែកលើភស្តុតាង និងព័ត៌មានដែលបានបង្កើតឡើងតាមរយៈក្របខ័ណ្ឌ MEL
- ដើម្បីច្បាមយក និងយល់ពីវឌ្ឍនភាពនៃលទ្ធផលរំពឹងទុក តាមរយៈការរាយការណ៍ប្រកបដោយសង្គតិភាព និងគុណភាពជូន គ.ជ.ប.ជ
- ដើម្បីច្បាមយក ចែករំលែក និងលើកកម្ពស់ការអនុវត្តល្អ និងមេរៀនដែលបានរៀនសូត្រ
- ដើម្បីកំណត់បរិមាណ និងគុណភាពនៃការអនុវត្តសកម្មភាពដែលបានកំណត់ ក្នុងផែនការយុទ្ធសាស្ត្រជាតិ
- ដើម្បីបង្កើតព័ត៌មានដែលត្រូវបានបែងចែកជាប្រភេទគ្រប់គ្រាន់ និងឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ។

ក្របខ័ណ្ឌនេះត្រូវបានរចនាឡើង ដើម្បីគ្របដណ្តប់លើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងអស់ដែលបានអនុវត្តនៅកម្ពុជា ឬដោយទីភ្នាក់ងាររដ្ឋាភិបាល និងដៃគូកម្ពុជា។ សកម្មភាពទាំងនោះមានបំណងរួមចំណែកដល់ការសម្រេចបានលទ្ធផលនៃផែនការយុទ្ធសាស្ត្រជាតិ និងរួមចំណែកដល់ការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាក្រោមអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP)។ គណនេយ្យភាពលាតសន្ធឹងដល់លទ្ធផលនៅចុងយុទ្ធសាស្ត្រ (EOSO) នាដំណាច់ឆ្នាំ ២០២៨។

ផែនការយុទ្ធសាស្ត្រជាតិនឹងត្រូវបានអនុវត្តដោយសមាជិក គ.ជ.ប.ជ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពោលគឺក្រុមការងារអន្តរក្រសួងទាំង ៦ នៅថ្នាក់ជាតិ ដោយមានការសម្របសម្រួលពីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមការងារនៃនាយកដ្ឋាន និងស្ថាប័នទាំង ៦ នៅថ្នាក់ក្រោមជាតិ ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋាន គ.រ.ប.ជ។

## ៣.២ គោលការណ៍

ក្របខ័ណ្ឌ MEL នេះបន្សុីគ្នានឹងគុណតម្លៃ និងគោលការណ៍ស្នូលដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រជាតិ។

- ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល
- គោលការណ៍គោរពសិទ្ធិមនុស្សជាមូលដ្ឋាន
- គោលការណ៍មូលដ្ឋាននៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI)
- ការចូលរួមដោយសកម្មពីសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ
- កិច្ចសហប្រតិបត្តិការជាពហុវិស័យ និងភាពជាដៃគូ
- ការត្រួតពិនិត្យ និងវាយតម្លៃជាប្រព័ន្ធ និងមាននិរន្តរភាព

បន្ថែមលើគោលការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ គោលការណ៍នៃក្របខ័ណ្ឌ MEL មានដូចខាងក្រោម៖

## ៣.៣ អ្នកប្រើប្រាស់គោលដៅនៃក្របខ័ណ្ឌ MERL

អ្នកប្រើប្រាស់គោលដៅនៃក្របខ័ណ្ឌ MERL នេះ និងតម្រូវការព័ត៌មាន មានបង្ហាញក្នុងតារាងទី ១។ អ្នកប្រើប្រាស់ចម្បងគឺអ្នកដែលត្រូវការព័ត៌មានវាយតម្លៃស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និងអ្នកដែលនឹងប្រើប្រាស់ព័ត៌មានទាំងនោះ។ ជាទូទៅ អ្នកប្រើប្រាស់ចម្បងរួមបញ្ចូលអ្នកដែលកំពុងអនុវត្តផែនការយុទ្ធសាស្ត្រជាតិ អ្នកដែលកំពុងផ្តល់មូលនិធិដល់ការអនុវត្តសកម្មភាព។ អ្នកប្រើប្រាស់បន្ទាប់បន្សំអាចនឹងអានរបាយការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ប៉ុន្តែក្របខ័ណ្ឌ MEL មិនត្រូវបានបង្កើតឡើងដើម្បីបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ទាំងនេះនោះទេ។

តារាងទី ១ ៖ អ្នកប្រើប្រាស់ក្របខ័ណ្ឌ MEL

| ប្រភេទអ្នកប្រើប្រាស់ | នរណា | តម្រូវការព័ត៌មាន |
|---|---|---|
| សំខាន់ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ▪ លទ្ធផល និងភស្តុតាងនៃលទ្ធផលរំពឹងទុកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ<br>▪ វឌ្ឍនភាពធៀបនឹងលទ្ធផលរយៈពេលខ្លី និងលទ្ធផលរយៈពេលមធ្យម<br>▪ វឌ្ឍនភាពធៀបនឹងការរំពឹងទុកលើសមិទ្ធកម្ម<br>▪ ព័ត៌មានអំពីការអនុវត្តល្អ និងមេរៀនដែលបានរៀនសូត្រ<br>▪ ភស្តុតាងនៃកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ |
| | ក្រសួង និងស្ថាប័នជាសមាជិក គ.ជ.ប.ជ | |
| | គណៈកម្មាធិការរាជធានី/ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | |
| បន្ទាប់បន្សំ | ដៃគូអភិវឌ្ឍន៍អន្តរជាតិ តំបន់ និងជាតិផ្សេងទៀត | ▪ ភស្តុតាងនៃវឌ្ឍនភាព<br>▪ លទ្ធផលចុងក្រោយ<br>▪ ព័ត៌មានអំពីការអនុវត្តល្អ និងមេរៀនដែលបានរៀនសូត្រ |
| | អ្នកពាក់ព័ន្ធផ្សេងទៀត រួមទាំងវិស័យឯកជន សហគមន៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ▪ ភស្តុតាងនៃការចូលរួម<br>▪ លទ្ធផលនៃលទ្ធផលរំពឹងទុក<br>▪ ព័ត៌មានអំពីការអនុវត្តល្អ និងមេរៀនដែលបានរៀនសូត្រ |
| | មន្ត្រីរដ្ឋាភិបាលផ្សេងទៀតក្រៅប្រព័ន្ធយុត្តិធម៌ | |
| | ជនរងគ្រោះ-ជនដែលធ្លាប់រងគ្រោះ | ▪ ការរួមចំណែករបស់ជនរងគ្រោះ-ជនដែលធ្លាប់រងគ្រោះ<br>▪ ព័ត៌មានអំពីការអនុវត្តល្អ និងមេរៀនដែលបានរៀនសូត្រ |

## ៣.៤ ហានិភ័យ និងការសន្មត

អាចមានហានិភ័យ និងការសន្មតពាក់ព័ន្ធនឹងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ដែលត្រូវពិចារណាក្នុងការអនុវត្តក្របខ័ណ្ឌ MERL។ ម៉ាទ្រីសហានិភ័យ (ឧបសម្ព័ន្ធ ង) នឹងត្រូវបានតាមដាន និងធ្វើបច្ចុប្បន្នភាពរៀងរាល់ ៦ ខែម្តងក្នុងរបាយការណ៍របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

នៅពេលដែលផែនការយុទ្ធសាស្ត្រជាតិត្រូវបានបង្កើតឡើង និងទ្រឹស្តីនៃការផ្លាស់ប្តូរត្រូវបានកែសម្រួលពីផែនការនេះ។ វាជាទ្រឹស្តីស្តីពីរបៀបដែលយើងរំពឹងទុកចំពោះការផ្លាស់ប្តូរ ប្រសិនបើអ្វីៗទាំងអស់ដំណើរការទៅតាមផែនការ។ ក្នុងការបង្កើត និងអនុវត្តទ្រឹស្តីនៃការផ្លាស់ប្តូរនេះ ឬក្នុងការអនុវត្តផែនការ

យុទ្ធសាស្ត្រជាតិ យើងមានការសន្មតជាច្រើនថា លទ្ធផលនីមួយៗនឹងកើតឡើង ហើយនឹងរួមចំណែកដល់ការសម្រេចបានលទ្ធផលនៅចុងយុទ្ធសាស្ត្រ (EOSO)។

ខាងក្រោមនេះជាការសន្មតលទ្ធផលសំខាន់ៗចេញពីទ្រឹស្តីនៃការផ្លាស់ប្តូរ។ យើងសន្មតថា៖

- [បញ្ចូលការសន្មតនៅទីនេះ]

## ៤.វិធីសាស្ត្រតាមដាន និងវាយតម្លៃ

### ៤.១ សំណួរវាយតម្លៃសំខាន់ៗ

សំណួរវាយតម្លៃសំខាន់ៗ (KEQs) ជាសំណួរគោលដែលជាត្រីវិស័យនៃក្របខ័ណ្ឌ MEL។ សំណួរទាំងនេះផ្តល់ការណែនាំសម្រាប់ការរៀបចំផែនការសកម្មភាព ការគ្រប់គ្រង និងការរៀនសូត្រ។ KEQs ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងគោលបំណងចម្បងៗនៃក្របខ័ណ្ឌ MERL និងតម្រូវការព័ត៌មានរបស់អ្នកប្រើប្រាស់ចម្បងនៃក្របខ័ណ្ឌនេះ។ បន្ទាប់មកគឺការកំណត់សំណួរបន្ទាប់បន្សំ និងសូចនាករអាទិភាពដែលពាក់ព័ន្ធ ដើម្បីបង្កើតមូលដ្ឋាននៃការប្រមូលទិន្នន័យ អ្វីដែលត្រូវតាមដាន និងប្រមូលភស្តុតាង ដើម្បីឆ្លើយតបនឹង KEQs។ សំណួរទាំងនេះក៏នឹងគាំទ្រដល់ការរាយការណ៍វឌ្ឍនភាព និងដំណើរការរៀនសូត្រផងដែរ។

តារាងទី ២ ៖ សំណួរវាយតម្លៃសំខាន់ៗ សំណួរបន្ទាប់បន្សំ និងសូចនាករ

| សំណួរវាយតម្លៃសំខាន់ៗ | សំណួរបន្ទាប់បន្សំ | សូចនាករអាទិភាព |
|---|---|---|
| KEQ1: តើយុទ្ធសាស្ត្ររបស់យើងក្រោមផែនការយុទ្ធសាស្ត្រជាតិមានប្រសិទ្ធភាពកម្រិតណាក្នុងការសម្រេចបានលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយ?<br><br>ប្រសិទ្ធភាព | ១.១ តើសកម្មភាពអ្វីខ្លះដែលត្រូវបានអនុវត្ត នៅទីណា និងដោយនរណា?<br>១.២ តើមនុស្សប៉ុន្មាននាក់ (បែងចែកជាប្រភេទសមស្រប) ដែលត្រូវបានគ្របដណ្តប់?<br>១.៣ តើយើងបានរៀនសូត្រអ្វីខ្លះអំពីអ្វីដែលមានប្រសិទ្ធភាពក្នុងការទប់ស្កាត់អំពើជួញដូរ ការផ្តន្ទាទោសអ្នកជួញដូរមនុស្ស និងការការពារជនរងគ្រោះ?<br>១.៤ តើយើងសម្រេចបានលទ្ធផលរំពឹងទុកក្នុងកម្រិតណា? | ១.ចំនួនសកម្មភាពដែលបានបញ្ចប់ (បែងចែកតាមប្រភេទ ទីតាំង យុទ្ធសាស្ត្រ)<br>២.ចំនួនអ្នកចូលរួម (បែងចែកតាមភេទ ពិការភាព ប្រភេទអ្នកពាក់ព័ន្ធ វិស័យ ទីតាំង)<br>៣....<br>៤.... |

| | | |
|---|---|---|
| KEQ2: តើយើងបានរួមចំណែកប្រកបដោយប្រសិទ្ធភាពកម្រិតណា និងដោយរបៀបណា ក្នុងការបង្ការអំពើជួញដូរមនុស្ស ការផ្តន្ទាទោសអ្នកជួញដូរមនុស្ស និងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ?<br><br>ការរួមចំណែក | ២.១ តើគោលនយោបាយ ប្រព័ន្ធ ឬសមត្ថភាពអ្វីខ្លះដែលត្រូវបានបង្កើតឡើង និងអនុវត្ត?<br>២.២ តើមានការសម្រេចបានការផ្លាស់ប្តូរអ្វីខ្លះពាក់ព័ន្ធនឹងចំណេះដឹង ឥរិយាបថ ការអនុវត្ត និងគោលនយោបាយ ដោយសារការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ?<br>២.៣ តើជនរងគ្រោះ និងជនដែលធ្លាប់រងគ្រោះដោយអំពើជួញដូរមនុស្ស កំពុងទទួលបានអត្ថប្រយោជន៍ពីសេវាគាំទ្រសមស្រប ក្នុងកម្រិតណា?<br>២.៤ តើសកម្មភាពរបស់យើងបានធ្វើឱ្យមានភាពខុសប្លែកអ្វីខ្លះចំពោះការបង្ការទប់ស្កាត់ ការអនុវត្តច្បាប់ និងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស? | ៥.ក្រសួង និងស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានការយល់ដឹង និងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>៦....<br>៧.... |
| KEQ3: តើកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូកំពុងកែលម្អការឆ្លើយតបរបស់យើងចំពោះការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការអនុវត្តច្បាប់ និងការការពារជនរងគ្រោះ ក្នុងកម្រិតណា ?<br><br>ភាពជាដៃគូ | ៣.១ តើអ្នកពាក់ព័ន្ធនៅក្រៅរដ្ឋាភិបាល រួមទាំងក្រុមជួបការលំបាក និងជនរងគ្រោះ-ជនដែលធ្លាប់រងគ្រោះ កំពុងជះឥទ្ធិពលលើច្បាប់ គោលនយោបាយ និងការអនុវត្តដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងកម្រិតណា?<br>៣.២ តើទីភ្នាក់ងាររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ បានសហការគ្នា និងចែករំលែកចំណេះដឹង ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែង ឬសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ពួកគេ ក្នុងកម្រិតណា និងដោយរបៀបណា?<br>៣.៣ តើទីភ្នាក់ងារពាក់ព័ន្ធ ទទួលបានព័ត៌មានពីនិន្នាការថ្មី និងភស្តុតាងនៃការអនុវត្តល្អក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិរបស់ពួកគេ ក្នុងកម្រិតណា? | ៨.ករណីនៃការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល រួមទាំងអ្នកតស៊ូមតិដើម្បីជនរងគ្រោះ និងវិស័យឯកជន<br>៩.ឧទាហរណ៍នៃការឆ្លើយតបកាន់តែប្រសើរទៅនឹងអំពើជួញដូរមនុស្សដោយសារភាពជាដៃគូ ឬកិច្ចសហការរវាងទីភ្នាក់ងាររដ្ឋាភិបាល និង/ឬមិនមែនរដ្ឋាភិបាល<br>១០.... |

## ៤.២ អនុក្រមនៃការតាមដាន

ផែនការយុទ្ធសាស្ត្រជាតិបានទទួលស្គាល់សារៈសំខាន់នៃការមានប្រព័ន្ធ 'ត្រួតពិនិត្យ វាយតម្លៃជាប្រព័ន្ធ និងមាននិរន្តរភាព' រឹងមាំមួយដើម្បីកំណត់អំពីបរិមាណ និងគុណភាពនៃការអនុវត្តសកម្មភាព។ វិធីសាស្ត្រតាមដាននឹងមានការចូលរួម តាមរយៈការប្រើប្រាស់ប្រព័ន្ធប្រមូលទិន្នន័យដែលមានស្រាប់ ហើយនឹងផ្អែកលើគោលការណ៍នៃក្របខ័ណ្ឌ MEL ដែលធូររលុង និងសមស្របនឹងគោលបំណង។ ផែនការយុទ្ធសាស្ត្រជាតិរួមបញ្ចូលសកម្មភាពលម្អិត និងសូចនាករចំនួន ៨២ ក្នុងចំណោមយុទ្ធសាស្ត្រទាំង ៤។ ជាសំណើ ក្របខ័ណ្ឌ MERL នេះនឹងចាប់ផ្តើមពីមូលដ្ឋានតូច និងប្រមូលតែទិន្នន័យដែលចាំបាច់ និងជាអាទិភាពប៉ុណ្ណោះដើម្បីគាំទ្រដល់ការរាយការណ៍អំពីវឌ្ឍនភាព និងការយល់ដឹងអំពីលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ។ តារាងទី ២ បង្ហាញពីសូចនាករអាទិភាពដែលបានកំណត់ក្នុងអំឡុងសិក្ខាសាលាខែវិច្ឆិកា ដែលបានដកស្រង់ពីកម្រងសូចនាករ (ឧបសម្ព័ន្ធ គ) ដែលមានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រជាតិ។

## ៤.៣ វិធីសាស្ត្រតាមដាន

ការតាមដានពាក់ព័ន្ធនឹងការប្រមូលទិន្នន័យបែបបរិមាណវិស័យ និងគុណវិស័យជាបន្តបន្ទាប់ដើម្បីស្វែងយល់ពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ក្នុងការផ្តល់លទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយដែលបានកំណត់។ នឹងមានវិធីសាស្ត្រផ្សេងៗក្នុងការប្រមូលព័ត៌មានស្តីពីលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយ ក៏ដូចជាការច្បាមយកមេរៀនដែលបានរៀនសូត្រ។ តារាងទី ៣ បង្ហាញពីវិធីសាស្ត្រ និងឧបករណ៍ប្រមូលទិន្នន័យដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌ MEL នេះ។

តារាងទី ៣ ៖ វិធីសាស្ត្រ និងឧបករណ៍ប្រមូលទិន្នន័យ

| វិធីសាស្ត្រ / ឧបករណ៍ | ការពណ៌នា | រយៈពេល | អ្នកអនុវត្ត |
|---|---|---|---|
| | | | |
| | | | |
| | | | |

### ការប្រមូលទិន្នន័យបែងចែកជាប្រភេទ

តាមដែលអាចធ្វើទៅបាន ព័ត៌មាននឹងត្រូវបានបែងចែកជាប្រភេទដូចខាងក្រោម៖

- ភេទ - ប្រុស ស្រី ផ្សេងៗ
- ក្រុមអាយុ
- ទីតាំងភូមិសាស្ត្រនៃសកម្មភាព - កម្រិតរាជធានី ឬខេត្ត
- ពិចារណាប្រមូលព័ត៌មានអំពីស្ថានភាពពិការភាព

- ប្រភេទសកម្មភាព
- ប្រភេទទីភ្នាក់ងារអនុវត្តន៍ - រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឯកជន

## ៤.៤ ការវាយតម្លៃ

ការវាយតម្លៃ ឬការពិនិត្យឡើងវិញដោយឯករាជ្យលើផែនការយុទ្ធសាស្ត្រជាតិ នឹងត្រូវបានធ្វើឡើងដោយ គ.ជ.ប.ជ មុនដំណាច់ឆ្នាំ ២០២៨។ គោលបំណងគឺដើម្បីធ្វើការប៉ាន់ប្រមាណវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និងការវាយតម្លៃវឌ្ឍនភាពឆ្ពោះទៅសម្រេចបានលទ្ធផលរយៈពេលមធ្យម និងការរួមចំណែកដល់លទ្ធផលនៅចុងយុទ្ធសាស្ត្រ។

មុនការវាយតម្លៃនេះ លក្ខខណ្ឌយោងនឹងត្រូវបានបង្កើតដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមការពិគ្រោះយោបល់ជាមួយ ....។

## ៤.៥ ទិន្នន័យគោល និងការរំពឹងទុកលើសមិទ្ធកម្ម

[បញ្ចូលនៅត្រង់នេះ ប្រសិនបើចាំបាច់ត្រូវពិភាក្សាអំពីទិន្នន័យគោល]

### ការរំពឹងទុកលើសមិទ្ធកម្ម

ដើម្បីវាស់វែងវឌ្ឍនភាពនៃលទ្ធផលចុងក្រោយ ការរំពឹងទុកលើសមិទ្ធកម្មសំខាន់ៗត្រូវបានកំណត់ និងបង្ហាញក្នុងតារាងទី ៤។ ការរំពឹងទុកលើសមិទ្ធកម្ម ទាក់ទងនឹងសំណួរវាយតម្លៃសំខាន់ៗ ក្រោមយុទ្ធសាស្ត្រនីមួយៗ។ ការបញ្ជាក់ការរំពឹងទុកលើសមិទ្ធកម្មសំខាន់ៗ នឹងជួយដល់ការសំយោគទិន្នន័យ និងការឆ្លើយសំណួរវាយតម្លៃសំខាន់ៗទាំងអស់ និងការវិនិច្ឆ័យវាយតម្លៃ។ ការកំណត់ការរំពឹងទុកលើសមិទ្ធកម្មសំខាន់ៗនេះចេញពីផែនការយុទ្ធសាស្ត្រជាតិដ៏គ្រប់ជ្រុងជ្រោយ នឹងសម្រួលដល់ការវាយតម្លៃដោយឯករាជ្យ ពោលគឺមានស្តង់ដារសមិទ្ធកម្មយ៉ាងច្បាស់លាស់។

តារាងទី ៤ ៖ ការរំពឹងទុកលើសមិទ្ធកម្ម បែងចែកតាមសំណួរវាយតម្លៃសំខាន់ៗ

| សំណួរវាយតម្លៃសំខាន់ៗ | ការរំពឹងទុកលើសមិទ្ធកម្ម |
|---|---|
| KEQ1: តើយុទ្ធសាស្ត្ររបស់យើងក្រោមផែនការយុទ្ធសាស្ត្រជាតិមានប្រសិទ្ធភាពកម្រិតណាក្នុងការសម្រេចបានលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយ?<br><br>ប្រសិទ្ធភាព | ១.ច្រើនជាង ៦០% នៃសកម្មភាពដែលបានគ្រោងទុក បានចាប់ផ្តើមឬបញ្ចប់ជារៀងរាល់ឆ្នាំ?<br>២. |
| KEQ2: តើយើងបានរួមចំណែកប្រកបដោយប្រសិទ្ធភាពកម្រិតណា និងដោយរបៀបណា ក្នុងការបង្ការអំពើជួញដូរមនុស្ស ការផ្តន្ទាទោសអ្នកជួញដូរមនុស្ស និងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស?<br><br>ការរួមចំណែក | ៣. |
| KEQ3: តើកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូកំពុងកែលម្អការឆ្លើយតបរបស់យើងចំពោះការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការអនុវត្តច្បាប់ និងការការពារជនរងគ្រោះ ក្នុងកម្រិតណា?<br><br>ភាពជាដៃគូ | ៤. |

នៅក្នុងរបាយការណ៍វឌ្ឍនភាព (ប្រចាំឆមាស និងប្រចាំឆ្នាំ) ការវាយតម្លៃវឌ្ឍនភាពធៀបនឹងការរំពឹងទុកលើសមិទ្ធកម្មនីមួយៗ និងវឌ្ឍនភាពឆ្ពោះទៅសម្រេចបានលទ្ធផលរយៈពេលមធ្យម នឹងប្រើប្រាស់មាត្រដ្ឋាននៃការវាយតម្លៃដែលបានបង្ហាញក្នុងតារាងទី ៥។

តារាងទី ៥ ៖ មាត្រដ្ឋាននៃការវាយតម្លៃដើម្បីវាយតម្លៃវឌ្ឍនភាពនៃលទ្ធផលចុងក្រោយ និងការរំពឹងទុកលើសមិទ្ធកម្ម

| | | |
|---|---|---|
| **សម្រេចបាន** | | សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ និងសម្រេចបានលទ្ធផលរយៈពេលមធ្យម ឬការរំពឹងទុកលើសមិទ្ធកម្ម។ |
| **សម្រេចបានមួយផ្នែក** | | សម្រេចបានវឌ្ឍនភាពមួយចំនួន និងកំពុងឆ្ពោះទៅសម្រេចបានលទ្ធផលរយៈពេលមធ្យម ឬការរំពឹងទុកលើសមិទ្ធកម្ម ប៉ុន្តែវឌ្ឍនភាពគឺតិចជាងការរំពឹងទុក។ |
| **មានបញ្ហាប្រឈម** | | មានការពន្យារពេល និងបញ្ហាប្រឈមមួយចំនួនក្នុងការសម្រេចបានលទ្ធផលរយៈពេលមធ្យម ឬការរំពឹងទុកលើសមិទ្ធកម្ម ប៉ុន្តែយើងរំពឹងថានឹងត្រឡប់ទៅរកប្រក្រតីភាពវិញ។ |
| **មានបញ្ហាប្រឈមខ្លាំង** | | មានការពន្យារពេល និង/ឬបញ្ហាប្រឈមគួរឱ្យកត់សម្គាល់ក្នុងការសម្រេចបានលទ្ធផលរយៈពេលមធ្យម ឬការរំពឹងទុកលើសមិទ្ធកម្ម។ |

# ៥.ការរាយការណ៍ និងការរៀនសូត្រ

## ៥.១ ការរាយការណ៍

ផ្នែកនេះផ្តល់នូវកម្រិតផ្សេងៗនៃការរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និងវឌ្ឍនភាពឆ្ពោះទៅសម្រេចបានលទ្ធផលនៅចុងយុទ្ធសាស្ត្រ។ យន្តការរាយការណ៍ដែលមានស្រាប់ជាមួយ គ.ជ.ប.ជ នឹងនៅបន្តអនុវត្ត ហើយប្រសិនបើចាំបាច់ នឹងត្រូវបានពង្រឹងបន្ថែមដើម្បីបញ្ចូលតម្រូវការទិន្នន័យថ្មីពីផែនការយុទ្ធសាស្ត្រជាតិចុងក្រោយ។

ខាងក្រោមនេះជាដំណើរការ និងក្របខ័ណ្ឌពេលវេលានៃការរាយការណ៍ ហើយឧបសម្ព័ន្ធ ឃ ផ្តល់នូវគំរូរបាយការណ៍ ក្រោមក្របខ័ណ្ឌ MEL នេះ។

[បញ្ចូលត្រង់នេះនូវដំណើរការ និងក្របខ័ណ្ឌពេលវេលារាយការណ៍ ដែលបានពិភាក្សាក្នុងអំឡុងសិក្ខាសាលា]

## ៥.២ ការរៀនសូត្រ

ផែនការយុទ្ធសាស្ត្រជាតិទទួលស្គាល់សារៈសំខាន់នៃការតាមដាន និងវាយតម្លៃ។ ក្របខ័ណ្ឌ MEL នេះកំពុងពង្រីកវិធីសាស្ត្រតាមដាន និងវាយតម្លៃ ដើម្បីបង្កើនការប្រើប្រាស់ និងការរៀនសូត្រពីការតាមដាន និងវាយតម្លៃ ឱ្យបានជាអតិបរមា។ វិធីសាស្ត្រ 'រៀនសូត្រ' នឹងធានាថា អ្នកប្រើប្រាស់ចម្បងនៃក្របខ័ណ្ឌ MEL នឹងពិនិត្យមើលទិន្នន័យតាមដាន វិភាគទិន្នន័យទាំងនោះ និងកែសម្រួលផែនការ និងសកម្មភាពដោយផ្អែកលើការរៀនសូត្ររបស់ពួកគេ។ ការណ៍នេះគឺដើម្បីបង្កើត 'ការរៀបចំការរៀនសូត្រ' ឬ 'វប្បធម៌នៃការរៀនសូត្រ' សម្រាប់ការគ្រប់គ្រងបត់បែនតាមស្ថានភាព។ តារាងទី ៦ ពណ៌នាអំពីវិធីសាស្ត្រដែលបានស្នើឡើងសម្រាប់ការកសាងវប្បធម៌នៃការរៀនសូត្រ ស្របតាមផែនការយុទ្ធសាស្ត្រជាតិ។

តារាងទី ៦ ៖ សកម្មភាព ឬព្រឹត្តិការណ៍រៀនសូត្រសម្រាប់ការគ្រប់គ្រងបត់បែនតាមស្ថានភាព

| ព្រឹត្តិការណ៍ | អ្នកចូលរួមគោលដៅ | គោលបំណង | ពេលវេលា |
|---|---|---|---|
| កិច្ចប្រជុំគម្រោង (ផ្ទៃក្នុង) | ក្រុមគម្រោងទាំងអស់ ឬអ្នកដែលកំពុងអនុវត្តផែនការយុទ្ធសាស្ត្រជាតិ នៅកម្រិតទីភ្នាក់ងារ | ដើម្បីចែករំលែក និងពិភាក្សាអំពីការធ្វើបច្ចុប្បន្នភាពសកម្មភាព៖<br>▪ វឌ្ឍនភាពធៀបនឹងផែនការការងារប្រចាំឆ្នាំ<br>▪ ហានិភ័យ និងការកាត់បន្ថយហានិភ័យ<br>▪ មេរៀនដែលបានរៀនសូត្រ<br>▪ ការផ្លាស់ប្តូរដែលបានស្នើឡើងចំពោះផែនការ ឬសកម្មភាពដែលត្រូវអនុវត្តបន្ត | ប្រចាំខែ |
| | | ▪ | |
| | | ▪ | |
| | | ▪ | |
| ការពិនិត្យឡើងវិញ និងការឆ្លុះបញ្ចាំង | | ដើម្បីចែករំលែក និងពិភាក្សាអំពី៖<br>▪ វឌ្ឍនភាពធៀបនឹងលទ្ធផល<br>▪ វឌ្ឍនភាពធៀបនឹងផែនការយុទ្ធសាស្ត្រជាតិ<br>▪ បញ្ហាប្រឈម ឧបសគ្គ និងគម្លាត<br>▪ របៀបដោះស្រាយឧបសគ្គ<br>▪ មេរៀនដែលបានរៀនសូត្រ<br>▪ សកម្មភាពដែលត្រូវអនុវត្តបន្ត | ប្រចាំឆមាស ឬប្រចាំឆ្នាំ |

## ៥.៣ ការអភិវឌ្ឍសមត្ថភាព MEL

គន្លឹះសម្រាប់ការអនុវត្តក្របខ័ណ្ឌ MEL នេះ គឺការកសាងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងទីភ្នាក់ងារជាសមាជិកគោលដៅ ស្តីពីការតាមដាន និងការរាយការណ៍។ ក្រុម MEL ដែលត្រូវបានចាត់តាំងនៅក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងសម្របសម្រួលការអនុវត្តក្របខ័ណ្ឌនេះ រួមទាំងសកម្មភាព MEL ដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រជាតិ (ឧបសម្ព័ន្ធ ច)។

# ៦.សកម្មភាព MEL និងការទទួលខុសត្រូវ

## ៦.១ សកម្មភាព MEL

[ផ្តល់សេចក្តីសង្ខេបនៃសកម្មភាព MEL សំខាន់ៗ ដូចមានរៀបរាប់ក្នុងផែនការយុទ្ធសាស្ត្រជាតិ]

## ៦.២ តួនាទី និងការទទួលខុសត្រូវ

ការទទួលខុសត្រូវពាក់ព័ន្ធនឹងការតាមដាន វាយតម្លៃ និងរៀនសូត្រត្រូវបានសង្ខេបក្នុងតារាង ៧។

តារាងទី ៧ ៖ ការទទួលខុសត្រូវក្នុងក្របខ័ណ្ឌ MEL

| តួនាទី | ការទទួលខុសត្រូវ |
|---|---|
| គ.ជ.ប.ជ | ▪ ត្រួតពិនិត្យយុទ្ធសាស្ត្រ និងការអនុវត្តទូទៅនៃកម្មវិធី ASEAN-ACT<br>▪ ផ្តល់ការណែនាំ និងការធានាគុណភាពលើការរាយការណ៍វឌ្ឍនភាព<br>▪ ប្រើប្រាស់ទិន្នន័យសម្រាប់ការគ្រប់គ្រង ការរៀបចំផែនការ និងការរាយការណ៍កម្មវិធី |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ▪ បង្កើត និងពិនិត្យឡើងវិញលើផែនការ MEL<br>▪ ត្រួតពិនិត្យ និងគ្រប់គ្រងការអនុវត្តផែនការ MEL<br>▪ គ្រប់គ្រងការរៀបចំផែនការ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងការរាយការណ៍វឌ្ឍនភាពរបស់កម្មវិធី ស្របតាមផែនការ MEL និងទ្រឹស្តីនៃការផ្លាស់ប្តូរដែលបានកែសម្រួល<br>▪ លើកកម្ពស់ និងកសាងវប្បធម៌ MEL នៅក្នុងក្រុម និងជាមួយដៃគូ |
| សមាជិក និងក្រុមការងារ គ.ជ.ប.ជ | ▪ សម្របសម្រួលការប្រមូលទិន្នន័យ និងចងក្រងទិន្នន័យក្នុងកម្មវិធីទាំងមូល និងរក្សាទុកមូលដ្ឋានទិន្នន័យដែលពាក់ព័ន្ធ<br>▪ គាំទ្រការអនុវត្ត និងការពិនិត្យឡើងវិញលើផែនការ MEL<br>▪ គាំទ្រការអនុវត្តសកម្មភាព MEL<br>▪ លើកកម្ពស់ និងគាំទ្រការកសាងវប្បធម៌ MEL |
| លេខាធិការដ្ឋាន គ.រខ/.ប.ជ | ▪ គាំទ្រការវិភាគទិន្នន័យ និងការរាយការណ៍វឌ្ឍនភាព<br>▪ គាំទ្រ និងចូលរួមក្នុងសកម្មភាព MEL<br>▪ ប្រើប្រាស់ទិន្នន័យសម្រាប់ការគ្រប់គ្រង ការរៀបចំផែនការ និងការរាយការណ៍កម្មវិធី<br>▪ គាំទ្រអង្គភាព MEL ក្នុងការកសាងវប្បធម៌ MEL នៅក្នុងកម្មវិធី ASEAN-ACT |
| អ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដៃគូអនុវត្តន៍ | ▪ លើកកម្ពស់ និងគាំទ្រការកសាងវប្បធម៌ MEL ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>▪ គាំទ្រការប្រមូល និងការបកស្រាយទិន្នន័យ នៅពេលមានការស្នើសុំ<br>▪ ចូលរួមក្នុងសកម្មភាព MEL របស់ គ.ជ.ប.ជ នៅពេលមានការអញ្ជើញ |

## ៧.ក្រមសីលធម៌ក្នុងការតាមដាន និងវាយតម្លៃ

ក្របខ័ណ្ឌនេះទទួលស្គាល់សារៈសំខាន់នៃក្រមសីលធម៌ក្នុងការតាមដាន វាយតម្លៃ និងរាយការណ៍។ ផែនការយុទ្ធសាស្ត្រជាតិ នឹងដោះស្រាយប្រកបដោយសក្តានុពលជាមួយជនងាយរងគ្រោះ ជនរងគ្រោះ-ជនដែលធ្លាប់រងគ្រោះ និងកុមារ។ ក្របខ័ណ្ឌនេះនឹងគោរពតាមការអនុវត្តប្រកបដោយក្រមសីលធម៌ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ការប្រមូល ការរក្សាទុក និងការរាយការណ៍ទិន្នន័យក្រោមក្របខ័ណ្ឌនេះ នឹងអនុវត្តតាមនីតិវិធីតឹងរ៉ឹងដើម្បីរក្សាការសម្ងាត់នៃព័ត៌មានដែលបានប្រមូល រក្សាទុក និងរាយការណ៍។

តើត្រូវមានការយល់ព្រមដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ឬទេ? - មុនពេលប្រមូលទិន្នន័យពីបុគ្គលណាម្នាក់សម្រាប់គោលបំណងតាមដាន និងវាយតម្លៃ អ្នកចូលរួមត្រូវបានតម្រូវឱ្យផ្តល់ការយល់ព្រមដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ (ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់)។

ការស្រាវជ្រាវ ការពិនិត្យឡើងវិញ និងការវាយតម្លៃ នឹងត្រូវផ្អែកតាម [បញ្ចូលគោលនយោបាយដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល នៅត្រង់នេះ]

# ឧបសម្ព័ន្ធ ក ៖ ទ្រឹស្តីនៃការផ្លាស់ប្តូរ

សេចក្តីព្រាងទ្រឹស្តីនៃការផ្លាស់ប្តូរនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨)

| | | | | |
|---|---|---|---|---|
| យុទ្ធសាស្ត្រ | យុទ្ធសាស្ត្រទី ១. លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ | យុទ្ធសាស្ត្រទី ២. បង្កើនគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ | យុទ្ធសាស្ត្រទី ៣. បង្កើនគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារជនរងគ្រោះ | យុទ្ធសាស្ត្រទី ៤. ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្ត |
| លទ្ធផលនៅចុងយុទ្ធសាស្ត្រ | EOSO 1: ក្រុមគោលដៅ ជាពិសេសក្រុមងាយរងគ្រោះមិនសូវងាយរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់ទម្រង | EOSO 2: ប្រព័ន្ធយុត្តិធម៌មានការឆ្លើយតបប្រកបដោយគុណភាព និងប្រសិទ្ធភាពទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ | EOSO 3: ជនរងគ្រោះទទួលបានសេវាគាំទ្រប្រកបដោយគុណភាពនិងសមស្រប | EOSO 4: អ្នកពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបង្កើនកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ បង្ក្រាបបទល្មើស និងគាំទ្រជនរងគ្រោះ |
| លទ្ធផលរយៈពេលមធ្យម | **EOSO 1 – ការបង្ការទប់ស្កាត់** | **EOSO 2 – ការអនុវត្តច្បាប់** | **EOSO 3 – កិច្ចការពារជនរងគ្រោះ** | **EOSO 4 – កិច្ចសហប្រតិបត្តិការ** |
| | ១.១ ក្រុមងាយរងគ្រោះ និងអ្នកពាក់ព័ន្ធដែលជាក្រុមអាទិភាពបាន ទទួលសារ និងកម្មវិធីផ្សព្វផ្សាយដែលមានគុណភាព និងស៊ីសង្វាក់គ្នា | ២.១ លិខិតុបករណ៍ច្បាប់ ត្រូវបានពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន និងការវិវត្តនៃឧក្រិដ្ឋកម្មជួញដូរមនុស្ស | ៣.១ ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានកំណត់អត្តសញ្ញាណប្រកបដោយប្រសិទ្ធភាព | ៤.១ វិស័យឯកជនកំពុងចូលរួម និងប្រឡូកយ៉ាងសកម្មក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស |
| | ១.២ ប្រជាជនគោលដៅមានការយល់ដឹងកាន់តែច្រើនស្តីពីការបង្ការទប់ស្កាត់ និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស | ២.២ វិស័យយុត្តិធម៌បានពង្រឹងយន្តការប្រមូលទិន្នន័យ និងរាយការណ៍ស្តីពីករណីអំពើជួញដូរមនុស្ស | ៣.២ ប្រព័ន្ធបញ្ជូនថ្នាក់ជាតិ ត្រូវបានបង្កើតឡើង និងអនុវត្ត | ៤.២ ទីភ្នាក់ងារយុត្តិធម៌ និងអ្នកពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កំពុងសហការគ្នាបង្ការទប់ស្កាត់ បង្ក្រាប និងឆ្លើយតបនឹងអំពើជួញដូរមនុស្ស |
| | ១.៣ តំបន់គោលដៅបានអភិវឌ្ឍកម្មវិធីអប់រំស្តីពីអំពើជួញដូរមនុស្សដែលគ្រប់ជ្រុងជ្រោយ និងមានគុណភាព | ២.៣ មន្ត្រីអនុវត្តន៍ច្បាប់បានពង្រឹងសមត្ថភាពស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ៣.៣ ប្រព័ន្ធគ្រប់គ្រងករណីជនរងគ្រោះត្រូវបានពង្រឹង | ៤.៣ អ្នកផ្តល់សេវាក្នុងរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល បានពង្រឹងកិច្ចសហប្រតិបត្តិការដោយតម្កល់ឧត្តមប្រយោជន៍របស់ជនរងគ្រោះនៅគ្រប់ដំណាក់កាល |
| | ១.៤ បានបង្កើត និងអនុវត្តកម្មវិធីយុទ្ធនាការ និងយន្តការបង្ការទប់ស្កាត់ស្តីពីការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារ | ២.៤ ប្រព័ន្ធយុត្តិធម៌បានពង្រីកការប្រើប្រាស់នីតិវិធីស្តាប់ចម្លើយតាមបែបកុមារមេត្រី | ៣.៤ ការស្តារនីតិសម្បទានជនរងគ្រោះផ្តោតលើចរិតលក្ខណៈ និងតម្រូវការរបស់បុគ្គល | ៤.៤ កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីត្រូវបានពង្រឹង និងមានប្រសិទ្ធភាព |
| លទ្ធផលរយៈពេលខ្លី | ច្បាប់ បទបញ្ញត្តិ និងគោលនយោបាយត្រូវបានអនុវត្តសម្រាប់ការធ្វើសមាហរណកម្ម ការផ្តន្ទាទោស និងការវិនិច្ឆ័យទោសអ្នកជួញដូរមនុស្ស និងអ្នកផ្សេងទៀតដែលពាក់ព័ន្ធក្នុងករណីជួញដូរមនុស្ស | | | |

# ឧបសម្ព័ន្ធ ខ ៖ សូចនាករដែលមានរៀបរាប់ក្នុងផែនការយុទ្ធសាស្ត្រជាតិ

| ចង្កោមសកម្មភាព/សកម្មភាពចម្បង | សូចនាករ |
|---|---|
| **យុទ្ធសាស្ត្រទី ១ ៖ លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ** | |
| **លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស** | |
| ១.១ រៀបចំ និងអនុវត្តវិធីសាស្ត្រ ឆ្ពោះទៅរកការផ្លាស់ប្តូរឥរិយាបថ អវិជ្ជមានដែលងាយបង្កភាពរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់ទម្រង់ | ១. ស្ថានភាព និងផលប៉ះពាល់នៃការធ្វើទេសន្តរប្រវេសន៍ចំពោះសង្គម ត្រូវបានតាមដានជាប្រចាំ និងផ្សព្វផ្សាយ<br>២. សេវាកម្មសម្រាប់ការគាំទ្រសុវត្ថិភាពទេសន្តរប្រវេសន៍ មានភាពប្រសើរឡើង<br>៣. ទិន្នន័យអំពីសិប្បកម្ម ធុរកិច្ច និងតម្រូវការកម្លាំងផលិតករ កម្មករ ត្រូវបានដាក់ផ្សព្វផ្សាយជាប្រចាំ<br>៤. វិធីសាស្ត្របង្ការ ទប់ស្កាត់យុវវ័យ និងកុមារប្រឈមភាពរងគ្រោះ ត្រូវបានផលិត |
| ១.២ លើកកម្ពស់គុណតម្លៃ និងសង្គតិភាពនៃសារ និងវិធីសាស្ត្រអប់រំផ្សព្វផ្សាយ ដោយផ្តោតការយកចិត្តទុកដាក់លើក្រុមដែលងាយរងគ្រោះ និងអ្នកពាក់ព័ន្ធជាអាទិភាព និងទម្រង់នៃបទល្មើសជួញដូរមនុស្ស ដែលកំពុងកើតមាន | ១. ពិនិត្យ បង្កើត និងដាក់ឱ្យប្រើប្រាស់ឧបករណ៍ សម្ភារ និងសាររួមសម្រាប់ប្រើប្រាស់ក្នុងការផ្សព្វផ្សាយ បង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ប្រកបដោយភាពច្បាស់លាស់ និងសង្គតិភាព ទៅតាមក្រុមគោលដៅជាក់លាក់នីមួយៗ<br>២. បានបង្កើត និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធផ្ទុកឧបករណ៍ សម្ភារ និងសាររួម ដែលអាចឱ្យអ្នកប្រើប្រាស់ និងក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងអង្គការដៃគូ ទាញយក និងផលិតឡើងវិញ |
| ១.៣ លើកកម្ពស់ការសម្រេចចិត្ត ជ្រើសរើសយកជម្រើសដែលល្អប្រសើរសម្រាប់ការទទួលបានការងារ និងមុខរបរសមរម្យ ជាពិសេសក្នុងចំណោមស្ត្រីវ័យក្មេង និងយុវជន ដើម្បីបង្ការភាពរងគ្រោះដោយអំពើជួញដូរមនុស្ស | ១. បានបង្កើនចំណេះដឹងដល់ប្រជាជនគោលដៅដែលអាចជួយឱ្យមានការសម្រេចចិត្តជ្រើសរើសយកជម្រើសប្រសើរ ចៀសផុតពីភាពរងគ្រោះដោយចំណាកស្រុកដោយប្រថុយប្រថាន និងដោយអំពើជួញដូរមនុស្ស |
| ១.៤ លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឌីជីថល ប្រកបដោយសុវត្ថិភាព | ១. ចំណេះដឹង និងការអនុវត្តពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឌីជីថលប្រកបដោយសុវត្ថិភាព ត្រូវបានផ្សព្វផ្សាយទូលំទូលាយដល់ប្រជាជនគោលដៅ<br>២. មានកិច្ចសហការប្រកបដោយប្រសិទ្ធភាពជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលក្នុងការចូលរួមបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស |

| ចង្កោមសកម្មភាព/សកម្មភាពចម្បង | សូចនាករ |
|---|---|
| | ៣. កិច្ចអន្តរាគមន៍ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពពាក់ព័ន្ធករណីរំលោភបំពានកេងប្រវ័ញ្ចតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឌីជីថល |
| ១.៥ ជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព វិធានការអធិការកិច្ចទីតាំងគោលដៅសង្ស័យពាក់ព័ន្ធអំពើជួញដូរមនុស្ស និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ | ១. គ្រប់ជំនាញតាមក្រសួង ស្ថាប័នពាក់ព័ន្ធ បានពង្រឹងការចុះតាមមូលដ្ឋាន ត្រួតពិនិត្យទីតាំងគោលដៅសង្ស័យ ដែលអាចកើតមានបទល្មើសជួញដូរ រំលោភបំពាន និងកេងប្រវ័ញ្ចផ្សេងៗ ប្រកបដោយប្រសិទ្ធភាពខ្ពស់ |
| ១.៦ ពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ (ការបណ្ដុះបណ្ដាលជំនាញគ្រប់គ្រងផ្នែកហិរញ្ញវត្ថុគ្រួសារ ផែនការជីវិត ជំនាញបំណិនជីវិត/ជំនាញទន់ និងភាពធន់ទប់ទល់នឹងបម្រែបម្រួលអាកាសធាតុជាដើម) | ១. ប្រជាជនគោលដៅទទួលបានចំណេះជំនាញចាំបាច់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងទ្រទ្រង់ជីវភាពគ្រួសារដោយពុំចាំបាច់ពឹងផ្អែកទាំងស្រុងលើការធ្វើចំណាកស្រុកដោយប្រថុយប្រថាន |
| ១.៧ ជំរុញការចូលរួមពីវិស័យឯកជនក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់ (មានជាអាទិ៍ ៖ វិស័យអប់រំ ទេសចរណ៍ ការងារកសិកម្ម ឧស្សាហកម្ម សិប្បកម្ម សុខាភិបាល មីក្រូហិរញ្ញវត្ថុ ដឹកជញ្ជូន ធនាគារ ប្រៃសណីយ៍ និងទូរគមនាគមន៍) | ១. កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមសាលារៀន ត្រូវបានអនុវត្ត<br>២. គ្រូទទួលបានការយល់ដឹងពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស<br>៣. វិស័យឯកជនបានចូលរួមយ៉ាងសកម្មក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស |
| ១.៨ វិធានការបង្ការទប់ស្កាត់ តាមរយៈការបង្កើនការយល់ដឹងអំពីច្បាប់ គោលនយោបាយ លិខិតុបករណ៍ និងបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធរាល់ទម្រង់នៃបទល្មើសជួញដូរមនុស្ស | ១. គ្រប់សមាសភាគពាក់ព័ន្ធ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ទទួលបានការយល់ដឹងពីខ្លឹមសារគោលនយោបាយពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កលល្បិចជនល្មើស និងផលប៉ះពាល់នៃទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន និងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស |
| ១.៩ ពង្រឹងការអនុវត្តវិធានការបង្ការទប់ស្កាត់ការជួញដូរមនុស្ស តាមរូបភាពអាពាហ៍ពិពាហ៍ ឬការជ្រើសរើសគូស្រករ | ១. ព័ត៌មានពីភាពរងគ្រោះតាមរយៈអាពាហ៍ពិពាហ៍ជាមួយជនបរទេស ត្រូវបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋគោលដៅ<br>២. អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសមិនស្របច្បាប់ ត្រូវបានកាត់បន្ថយ |
| ១.១០ ជំរុញការអនុវត្តវិធានការ ឆ្លើយតប និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ | ១. អ្នកសារព័ត៌មាន ពិធីករ សិល្បករ ផលិតករ ពាណិជ្ជករវិស័យសិល្បៈ ពាណិជ្ជករវិស័យទេសចរណ៍ វិស័យសេវាកម្សាន្ត និងភាគីពាក់ព័ន្ធ បានយល់ច្បាស់អំពីអំពើជួញដូរមនុស្ស |

| ចង្កោមសកម្មភាព/សកម្មភាពចម្បង | សូចនាករ |
| --- | --- |
| | ២. បានបង្កើតស្នាដៃអប់រំសង្គម ឱ្យរួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស គ្រប់រូបភាព ប្រកបដោយសីលធម៌វិជ្ជាជីវៈ<br>៣. ប្រជាជនគោលដៅយល់ដឹងអំពីការបង្ការទប់ស្កាត់ និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស |
| ១.១១ ពង្រឹងប្រសិទ្ធភាព វិសាលភាព និងគុណភាពនៃយុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈ រួមទាំងយុទ្ធនាការថ្នាក់ជាតិពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ១. កម្មវិធីអប់រំផ្សព្វផ្សាយទូលំទូលាយ ដល់ប្រជាពលរដ្ឋគ្រប់តំបន់គោលដៅ ត្រូវបានបង្កើតឡើងប្រកបដោយគុណភាពខ្ពស់ និងត្រូវបានអនុវត្តជាប្រចាំ |
| ១.១២ ពង្រឹង និងជំរុញការប្រើប្រាស់យន្តការរាយការណ៍ ដើម្បីឆ្លើយតបទាន់ពេលវេលាចំពោះអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំបាន ដែលពាក់ព័ន្ធ | ១. យន្តការរាយការណ៍ ដើម្បីឆ្លើយតបទាន់ពេលវេលាចំពោះអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំពាន ដែលពាក់ព័ន្ធ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយប្រជាជនគោលដៅ |
| ១.១៣ លើកកម្ពស់ការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ | ១. មជ្ឈមណ្ឌលទទួលពលករតាមព្រំដែន (មណ្ឌលទទួលពលករកំរៀង បាត់ដំបង មណ្ឌសំចតប៉ោយប៉ែត បន្ទាយមានជ័យ) ត្រូវបានពង្រឹងដើម្បីផ្តល់ព័ត៌មាន អំពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព និងសេវាដល់ពលករដែលវិលត្រឡប់ និងពលករត្រូវការស្វែង<br>យល់ និងប្រជាពលរដ្ឋតាមសហគមន៍<br>២. ឃុំ-សង្កាត់ មានផែនការសកម្មភាពបង្ការទប់ស្កាត់សម្រាប់អនុវត្ត<br>៣. គុណភាពនៃកម្មវិធីបណ្តុះបណ្តាល និងការបណ្តុះបណ្តាលមុនពេលចេញដំណើរ តាមបណ្តាទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវបានពង្រឹង និងអនុវត្ត<br>៤. បញ្ជីទិន្នន័យពាក់ព័ន្ធនឹងទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវបានធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយជាប្រចាំ<br>៥. ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវបានធ្វើអធិការកិច្ចជាប្រចាំ<br>៦. វិធានការចំពោះទីភ្នាក់ងារជ្រើសរើសឯកជន ដែលមិនអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរឹតបន្តឹង និងអនុវត្តយ៉ាងខ្ជាប់ខ្ជួន |

| ចង្កោមសកម្មភាព/សកម្មភាពចម្បង | សូចនាករ |
|---|---|
| ១.១៤ ពង្រឹងកិច្ចសហប្រតិបត្តិការ និងវិធានការគ្រប់គ្រងព្រំដែនរួមគ្នា និងពង្រឹងវិធានការជំនាញទប់ស្កាត់ការឆ្លងដែនខុសច្បាប់ | ១. វិធានការសហប្រតិបត្តិការជាមួយប្រទេសពាក់ព័ន្ធស្តីពីការពង្រឹងវិធានការជំនាញទប់ស្កាត់ការឆ្លងដែនខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់<br>២. ប្រព័ន្ធគ្រប់គ្រងទិន្នន័យលំហូរចេញ-ចូលរបស់ពលករ ត្រូវបានដំណើរការ |
| **ការបង្ការទប់ស្កាត់ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ** | |
| ១.១៥ ពង្រឹងប្រសិទ្ធភាព វិសាលភាព និងគុណភាពនៃយុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈដើម្បីបង្ការទប់ស្កាត់ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ | ១. ប្រសិទ្ធភាព វិសាលភាព និងគុណភាពនៃយុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈដើម្បីបង្ការទប់ស្កាត់ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ត្រូវបានពង្រឹង និងអនុវត្តយ៉ាងទូលំទូលាយដល់ប្រជាជនគោលដៅ |
| ១.១៦ លើកកម្ពស់ប្រព័ន្ធសុវត្ថិភាពកុមារ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារគ្រប់រូបភាព (ក្រសួងអប់រំ ៖ មុខវិជ្ជាអប់រំសុខភាពសិក្សា) | ១. ចំណេះដឹងស្តីពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ ត្រូវបានផ្សព្វផ្សាយ និងអនុវត្តនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ឯកជន និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូគ្រប់កម្រិត<br>២. បណ្តាញសុវត្ថិភាពការពារកុមារក្នុងសាលារៀន ត្រូវបានបង្កើត និងពង្រីកបន្ថែម |
| ១.១៧ ពង្រឹង និងជំរុញការប្រើប្រាស់យន្តការរាយការណ៍តាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ដើម្បីឆ្លើយតបទាន់ពេលវេលាចំពោះអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំពានកុមារគ្រប់ទម្រង់ | ១. យន្តការរាយការណ៍តាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ចំពោះអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំពានកុមារគ្រប់ទម្រង់ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយប្រជាជនគោលដៅ |
| ១.១៨ ជំរុញការអនុវត្តវិធានការពាក់ព័ន្ធនឹងកិច្ចការពារកុមារ (កម្មវិធីកុមារឆ្លាតវៃ និងសុវត្ថិភាពឌីជីថល-និយ័តករក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ វិធានការការពារសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ) និងគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ (ក្រុមប្រឹក្សាជាតិដើម្បីកុមារ) | ១. ប្រព័ន្ធបណ្តាញសង្គម និងប្រព័ន្ធឌីជីថល ត្រូវបានប្រជាជនគោលដៅប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការផ្សព្វផ្សាយព័ត៌មានស្តីពីទម្រង់ និងឧបាយកលនៃអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំពានកុមារ<br>២. ប្រព័ន្ធលេខទូរស័ព្ទបន្ទាន់ (hotline) ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋទូទៅតាមរយៈប្រព័ន្ធទូរស័ព្ទចល័ត (TRC)<br>៣. ប្រជាពលរដ្ឋប្រើប្រាស់លេខទូរស័ព្ទបន្ទាន់ (hotline) រាយការណ៍ ឬសុំកិច្ចអន្តរាគមន៍ជួយសង្គ្រោះពីអាជ្ញាធរមានសមត្ថកិច្ច |

| ចង្កោមសកម្មភាព/សកម្មភាពចម្បង | | សូចនាករ |
|---|---|---|
| **យុទ្ធសាស្ត្រទី ២ ៖ ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់** | | |
| ២.១ | សិក្សាស្រាវជ្រាវអំពីភាពប្រែប្រួល ឬទម្រង់ថ្មីៗនៃបទល្មើស ល្បិចកល និងបណ្តាញជនល្មើស រួមទាំងអំពើពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យា ដើម្បីកំណត់វិធានការទប់ស្កាត់ និងបង្ក្រាបឱ្យមានប្រសិទ្ធភាព | ១. លទ្ធផលនៃការសិក្សាស្រាវជ្រាវពីនិន្នាការ បម្រែបម្រួល ទម្រង់ថ្មីៗនៃបទល្មើស ល្បិចកល និងបណ្តាញជនល្មើស រួមទាំងអំពើពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យា និងបទល្មើសជួញដូរមនុស្ស ត្រូវបានផ្សព្វផ្សាយ<br>២. លទ្ធផលនៃការសិក្សាស្រាវជ្រាវត្រូវបានយកប្រើប្រាស់ដើម្បីកំណត់វិធានការបង្ក្រាបអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាប |
| ២.២ | ពិនិត្យ និងកែសម្រួលក្របខ័ណ្ឌច្បាប់ដើម្បីអាចឆ្លើយតបបានទៅនឹងបច្ចុប្បន្នភាព និងការវិវត្តនៃការជួញដូរមនុស្ស | ១. មាត្រាពាក់ព័ន្ធក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ ឬគោលនយោបាយពាក់ព័ន្ធត្រូវបានពិនិត្យឡើងវិញ ធ្វើការកែសម្រួល ឬធ្វើវិសោធនកម្ម យោងតាមករណីចាំបាច់ជាក់ស្តែង<br>២. នីតិវិធីក្នុងការផ្តល់សំណងជូនជនរងគ្រោះ ត្រូវបានអនុវត្ត |
| ២.៣ | ពង្រឹងយន្តការនៃការប្រមូលទិន្នន័យសំណុំរឿងជួញដូរមនុស្សពីដំណាក់កាលអយ្យការ រហូតដល់ដំណាក់កាលជំនុំជម្រះ | ១. ទិន្នន័យពាក់ព័ន្ធនឹងសំណុំរឿងជួញដូរមនុស្សគ្រប់ទម្រង់ ត្រូវបានប្រមូល ចងក្រង គ្រប់ដំណាក់កាល និងចែករំលែក/រាយការណ៍ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ សមស្រប តាមពេលវេលាកំណត់ ប្រកបដោយសុក្រឹតភាព និងសង្គតិភាព |
| ២.៤ | បន្តពង្រឹងកិច្ចសហការរវាងស្ថាប័ន និងមន្ត្រីជំនាញអនុវត្តច្បាប់សង្គមកិច្ច ជាមួយនឹងស្ថាប័នពាក់ព័ន្ធនៅក្នុងប្រទេសនិងក្រៅប្រទេស ដើម្បីរួមគ្នាជាបណ្តាញទប់ស្កាត់បង្ក្រាបឧក្រិដ្ឋកម្មជួញដូរមនុស្សឆ្លងដែន និងពង្រឹងការអនុវត្តច្បាប់ ផ្តន្ទាទោសជនល្មើស ការពារសិទ្ធិ និងឧត្តមប្រយោជន៍ជនរងគ្រោះ | ១. ការសម្របសម្រួល និងកិច្ចសហការមន្ត្រីអនុវត្តច្បាប់ និងស្ថាប័នអយ្យការ តុលាការ និងសេវាសង្គមមានភាពរលូន<br>២. សិទ្ធិ សេចក្តីថ្លៃថ្នូរ និងឧត្តមប្រយោជន៍ជនរងគ្រោះ ត្រូវបានការពារប្រកបដោយបរិយាបន្ន<br>៣. ឧក្រិដ្ឋជនប្រព្រឹត្តបទល្មើសជួញដូរមនុស្សគ្រប់ទម្រង់ត្រូវបានផ្តន្ទាទោសតាមច្បាប់ជាធរមាន |
| ២.៥ | ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់អំពីជំនាញពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការ លើការងារប្រឆាំងអំពើជួញដូរមនុស្សគ្រប់ដំណាក់កាល និងលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអនុវត្តច្បាប់ | ១. ក្រសួង ស្ថាប័ន ក្នុងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានយល់ដឹង និងមានសមត្ថភាពជាក់ និងអនុវត្តវិធានការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព<br>២. មន្ត្រីអនុវត្តច្បាប់ទទួលបានការបណ្តុះបណ្តាលសមត្ថភាព ជំនាញនីតិវិធីស៊ើបអង្កេត និងអនុវត្តការងារប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ |

| ចង្កោមសកម្មភាព/សកម្មភាពចម្បង | សូចនាករ |
|---|---|
| | ៣. មន្ត្រីជំនាញទទួលបានការបណ្តុះបណ្តាលពីសុវត្ថិភាពស្ត្រី និងកុមារ ក្នុងវិស័យទេសចរណ៍ និងបានយល់ដឹងអំពីច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| ២.៦ ជំរុញការអនុវត្ត និងតាមដានប្រសិទ្ធភាពនៃច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្ត អនុស្សរណៈ កិច្ចព្រមព្រៀង នីតិវិធីប្រតិបត្តិស្តង់ដារពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស រវាងស្ថាប័ន និង/ឬប្រទេសពាក់ព័ន្ធ ទាំងនៅកម្រិតជាតិ តំបន់ និងអន្តរជាតិ | |
| ២.៧ បន្តពង្រឹង និងយកចិត្តទុកដាក់ចំពោះចំណាត់ការសំណុំរឿងជួញដូរមនុស្សនៅគ្រប់ដំណាក់កាល | |
| ២.៨ ពិនិត្យលទ្ធភាពក្នុងការពង្រីកការប្រើប្រាស់នីតិវិធីស្តាប់ចម្លើយតាមបែបកុមារមេត្រី ជាពិសេសករណីពាក់ព័ន្ធនឹងកុមារ ឬអនីតិជន | |
| **យុទ្ធសាស្ត្រទី ៣ ៖ ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារជនរងគ្រោះ** | |
| ៣.១ ពង្រឹងប្រសិទ្ធភាពការកំណត់អត្តសញ្ញាណជនរងគ្រោះដើម្បីផ្តល់សេវាសមស្រប | ១. គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដើម្បីផ្តល់សេវាសមស្រប ត្រូវបានកែសម្រួល/ធ្វើបច្ចុប្បន្នភាព ប្រកាសឱ្យអនុវត្ត និងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយអនុលោមតាមច្បាប់ជាតិ គោលការណ៍តំបន់ និងអន្តរជាតិ ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>២. ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានផ្តល់សេវាសមស្របតាមស្ថានភាពជាក់ស្តែង ទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព<br>៣. សេវាត្រូវបានផ្តល់ដល់ជនរងគ្រោះ ដោយមានការយកចិត្តទុកដាក់ ពិចារណាលើគោលការណ៍ពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព បរិយាបន្នសង្គម និងឧត្តមប្រយោជន៍ជនរងគ្រោះ |
| ៣.២ ជំរុញការរៀបចំ និងការអនុវត្តប្រព័ន្ធបញ្ជូនថ្នាក់ជាតិ | ១. ប្រព័ន្ធបញ្ជូនថ្នាក់ជាតិត្រូវបានបង្កើត និងអនុវត្តដោយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព |

| ចង្កោមសកម្មភាព/សកម្មភាពចម្បង | សូចនាករ |
| --- | --- |
| | ២. សេវានៅក្នុងដំណាក់កាលនីមួយៗនៃប្រព័ន្ធបញ្ជូនថ្នាក់ជាតិ ត្រូវបានផ្តល់ដល់ជនរងគ្រោះ ដោយមានការយកចិត្តទុកដាក់ ពិចារណាលើគោលការណ៍ពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព បរិយាបន្នសង្គម និងឧត្តមប្រយោជន៍ជនរងគ្រោះ |
| ៣.៣ ពង្រឹងប្រព័ន្ធគ្រប់គ្រងករណីជនរងគ្រោះ | ១. ប្រព័ន្ធគ្រប់គ្រងករណីជនរងគ្រោះត្រូវបានបង្កើត និងអនុវត្តដោយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ ប្រកបដោយប្រសិទ្ធភាព<br>២. ទិន្នន័យពាក់ព័ន្ធនឹងជនរងគ្រោះត្រូវបានកត់ត្រា ផ្ទុក ចែករំលែក និងរាយការណ៍ប្រកបដោយសុក្រឹតភាព សង្គតិភាព ទាន់ពេលវេលា ដល់ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធដោយអនុលោមតាមគោលការណ៍គោរពសិទ្ធិឯកជនភាពរបស់ជនរងគ្រោះ |
| ៣.៤ ពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលឱ្យកាន់តែប្រសើរ ដើម្បីលើកកម្ពស់កិច្ចការពារផ្លូវច្បាប់ និងសេវាចាំបាច់សមស្របតាមឧត្តមប្រយោជន៍ជនរងគ្រោះគ្រប់ដំណាក់កាល។ | ១. ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលបានសេវាសមស្របប្រកបដោយគុណភាព<br>២. ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានធ្វើសមាហរណកម្មទៅសហគមន៍<br>៣. លិខិតបទដ្ឋានពាក់ព័ន្ធនឹងការផ្តល់នីតិសម្បទាដល់ជនរងគ្រោះ ត្រូវបានបង្កើត និងអនុវត្ត<br>៤. កិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ត្រូវបានពង្រឹង |
| ៣.៥ ពង្រឹងប្រសិទ្ធភាពការអនុវត្តវិធីសាស្ត្រផ្តល់កិច្ចគាំពារ និងផ្តល់សេវាជូនជនរងគ្រោះ តាំងពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលធ្វើសមាហរណកម្មដោយជោគជ័យ និងបិទករណីដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើក្រុមគោលដៅអាទិភាព មានជាអាទិ៍ កុមារ ស្ត្រី យុវវ័យ ក្រុមជនមានពិការភាព ជនដែលមានជំនឿសាសនា ជាតិពន្ធុ អត្តសញ្ញាណយេនឌ័រ និងភាសាដោយឡែក ជាដើម ដោយគ្មានការរើសអើង | ១. សមត្ថភាព ជំនាញ និងចំណេះដឹងរបស់មន្ត្រីសង្គមកិច្ច និងភាគីពាក់ព័ន្ធក្នុងការផ្តល់សេវា ត្រូវបានពង្រឹង<br>២. ប្រសិទ្ធភាពកិច្ចគាំពារ និងសេវាជូនជនរងគ្រោះត្រូវបានពង្រឹងបន្ថែមនៅគ្រប់ដំណាក់កាល<br>៣. សេវាសមស្របត្រូវបានផ្តល់ដល់ជនរងគ្រោះប្រកបដោយបរិយាបន្នត្រឹមត្រូវ ដោយគ្មានការរើសអើង |
| ៣.៦ ពង្រឹងប្រសិទ្ធភាព និងគុណភាពការស្តារនីតិសម្បទាជនរងគ្រោះ ដោយផ្តោតការយកចិត្តទុកដាក់លើលក្ខណៈដោយឡែក ឬស្ថានភាពដោយឡែកៗពីគ្នា មានជាអាទិ៍ ទារក កុមារ ស្ត្រីវ័យក្មេង ស្ត្រី | ១. ប្រសិទ្ធភាព និងគុណភាពនៃសេវាពាក់ព័ន្ធនឹងការស្តារនីតិសម្បទាជនរងគ្រោះ ត្រូវបានពង្រឹងដោយមានការយកចិត្តទុកដាក់ ពិចារណាលើគោលការណ៍ពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព បរិយាបន្នសង្គម និងឧត្តមប្រយោជន៍ជនរងគ្រោះ |

| ចង្កោមសកម្មភាព/សកម្មភាពចម្បង | | សូចនាករ |
|---|---|---|
| | មានផ្ទៃពោះ ស្ត្រីមានកូនតូច ជនចាស់ជរា អ្នកមានពិការភាព ភាពខុសគ្នានៃយេនឌ័រ ជាដើម | ២. ជនធ្លាប់រងគ្រោះ ត្រូវបានស្តារនីតិសម្បទា រស់នៅប្រកបដោយសុវត្ថិភាព និងភាពរីករាយក្នុងគ្រួសារ និងសហគមន៍ |
| **យុទ្ធសាស្ត្រទី ៤ ៖ ការពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា** | | |
| ៤.១ | រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ប្រចាំឆ្នាំ និងពង្រឹងយន្តការ | ១. ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ត្រូវបានបង្កើតឡើង បានអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ<br>២. រចនាសម្ព័ន្ធ និងយន្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានពង្រឹង និងកែលម្អ |
| ៤.២ | ពង្រឹងរចនាសម្ព័ន្ធ និងសមត្ថភាពស្ថាប័ន អង្គភាព និងអង្គការដៃគូអនុវត្ត | ១. របៀបរបបការងារត្រូវបានពង្រឹង<br>២. កិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ត្រូវបានធ្វើឡើងយ៉ាងទៀងទាត់<br>៣. របាយការណ៍កិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ត្រូវបានផលិត<br>៤. មន្ត្រីលេខាធិការដ្ឋាន គរបជ/គខបជ ទទួលបានការបណ្តុះបណ្តាល<br>៥. មន្ត្រីនគរបាលយុត្តិធម៌ទទួលបានការបណ្តុះបណ្តាលជំនាញក្បួននីតិវិធីប្រតិបត្តិពាក់ព័ន្ធ |
| ៤.៣ | ប្រមូល ចងក្រង និងកសាងប្រព័ន្ធទិន្នន័យ ដើម្បីជាមូលដ្ឋាននៃការវិភាគលើកទិសដៅអនុវត្តផ្សព្វផ្សាយ និងផ្លាស់ប្តូរជាមួយប្រទេសពាក់ព័ន្ធ | ១. យន្តការក្នុងការប្រមូលចងក្រង គ្រប់គ្រង និងផ្លាស់ប្តូរទិន្នន័យ ត្រូវបានបង្កើត និងដំណើរការជាប្រព័ន្ធ<br>២. កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរ និងសមត្ថកិច្ច នៃបណ្តាប្រទេសពាក់ព័ន្ធ ត្រូវបានពង្រឹង និងបង្កើនប្រសិទ្ធភាព<br>៣. របាយការណ៍បង្ក្រាបប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ត្រូវបានផលិត<br>៤. របាយការណ៍ជនរងគ្រោះដោយអំពើជួញដូរមនុស្សប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ត្រូវបានផលិត និងផ្សព្វផ្សាយ |
| ៤.៤ | កសាងបទដ្ឋានគតិយុត្ត និងអនុស្សរណៈ កិច្ចព្រមព្រៀង និងស្តង់ដានីតិវិធីប្រតិបត្តិនានាជាមួយប្រទេសពាក់ព័ន្ធ | ១. បទដ្ឋានគតិយុត្ត ស្តង់ដានីតិវិធីប្រតិបត្តិ និងកិច្ចព្រមព្រៀងអនុវត្តសកម្មភាពស្តីពីការបង្ការទប់ស្កាត់ អនុវត្តច្បាប់ និងជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានបង្កើត និងចុះហត្ថលេខាជាមួយប្រទេសពាក់ព័ន្ធ |
| ៤.៥ | ពង្រឹងកិច្ចសហប្រតិបត្តិការ និងសមត្ថភាពជំនាញ ជាមួយប្រទេសពាក់ព័ន្ធ និងជាអន្តរជាតិ ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាបអំពើជួញដូរ | ១. អនុស្សរណៈ កិច្ចព្រមព្រៀង ត្រូវបានអនុវត្ត<br>២. បញ្ហាប្រឈមក្នុងការអនុវត្ត ត្រូវបានរកឃើញ និងដោះស្រាយ |

| | ចង្កោមសកម្មភាព/សកម្មភាពចម្បង | សូចនាករ |
|---|---|---|
| | មនុស្សឆ្លងដែន ផ្តល់អន្តរាគមន៍ជួយជនរងគ្រោះ និងជំរុញការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី | ៣. កិច្ចប្រជុំទ្វេភាគី ពហុភាគី ត្រូវបានរៀបចំទៀងទាត់ |
| ៤.៦ | ធ្វើវិសោធនកម្ម ឬ/និងរៀបចំសេចក្តីព្រាងច្បាប់ និងគោលនយោបាយជាតិឆ្លើយតបនឹងបញ្ហាថ្មី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស | ១. ឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធ ត្រូវបានកែលម្អក្នុងករណីចាំបាច់សម្រាប់ជាជំនួយដល់ការអនុវត្ត<br>២. ច្បាប់ និងគោលនយោបាយថ្មីៗ ត្រូវបានបង្កើតឡើងសម្រាប់អនុវត្តឆ្លើយតបទៅតាមតម្រូវការចាំបាច់ |

# ឧបសម្ព័ន្ធ គ ៖ វិធីសាស្រ្ត និងឧបករណ៍ប្រមូលទិន្នន័យ

សេចក្ដីព្រាងនេះត្រូវបំពេញបន្ថែម

| វិធីសាស្រ្តប្រមូលទិន្នន័យ | ឧបករណ៍ពាក់ព័ន្ធ | ការពិចារណាលើការរចនា | ភាពញឹកញាប់ | ការទទួលខុសត្រូវ | សូចនាករពាក់ព័ន្ធ |
|---|---|---|---|---|---|
| ការតាមដានសកម្មភាព | មើលឧបសម្ព័ន្ធរង គ.១ | | ការប្រមូលជាបន្តបន្ទាប់ និងការចងក្រងប្រចាំខែ | | ➢ |
| កម្រងសំណួរស្ដីពីយោបល់ត្រឡប់ | មើលឧបសម្ព័ន្ធរង គ.៣ | សម្រាប់តែព្រឹត្តិការណ៍ ឬសកម្មភាពគោលដៅប៉ុណ្ណោះ។ យោបល់ត្រឡប់នឹងត្រូវបានប្រមូលបន្ទាប់ពីព្រឹត្តិការណ៍នីមួយៗ។ | ការប្រមូលជាបន្តបន្ទាប់ និងការចងក្រងប្រចាំខែ | | ➢ ទាំងអស់ |
| ស្វ័យវាយតម្លៃរបស់ដៃគូ និងការស្ទង់មតិចំគោលដៅ | មើលឧបសម្ព័ន្ធរង គ.៤ | កម្រងសំណួរសមស្របតាមគោលបំណងដែលរៀបចំឡើងដោយខ្លួនឯង ឬវគ្គជាក្រុមដែលត្រូវធ្វើឡើងក្នុងអំឡុងព្រឹត្តិការណ៍ និង/ឬសិក្ខាសាលាពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងរបស់ដៃគូ។ លទ្ធផលនឹងរួមបញ្ចូលទាំងព័ត៌មានបែបបរិមាណវិស័យ និងគុណវិស័យ ។ | ប្រចាំឆ្នាំ | | ➢ ទាំងអស់ |
| រឿងរ៉ាវនៃការផ្លាស់ប្ដូរ ឬការប្រមូលលទ្ធផល | មើលឧបសម្ព័ន្ធរង គ.៥ | ការប្រមូលលទ្ធផលត្រូវបានរួមបញ្ចូលក្នុងប្លង់សិក្ខាសាលាពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំង។ | ប្រចាំឆ្នាំ | | ➢ |
| សិក្ខាសាលាពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំង | ប្រើប្រាស់ប្លង់សិក្ខាសាលាទូទៅ | ប្រភពព័ត៌មានសម្រាប់រឿងរ៉ាវនៃការផ្លាស់ប្ដូរលទ្ធផល និងករណីសិក្សាតាមដានបន្ត | ប្រចាំឆមាស | | ➢ ទាំងអស់ |

| វិធីសាស្ត្រប្រមូលទិន្នន័យ | ឧបករណ៍ពាក់ព័ន្ធ | ការពិចារណាលើការរចនា | ភាពញឹកញាប់ | ការទទួលខុសត្រូវ | សូចនាករពាក់ព័ន្ធ |
|---|---|---|---|---|---|
| របាយការណ៍ស្រាវជ្រាវ របាយការណ៍ទីប្រឹក្សា របាយការណ៍សិក្សា របាយការណ៍សង្ខេបគោលនយោបាយ និងឯកសារ សម្ភារៈ ឬផលិតផលពាក់ព័ន្ធ | | ច្បាប់ចម្លងនៃរបាយការណ៍ស្រាវជ្រាវ របាយការណ៍ទីប្រឹក្សា របាយការណ៍សិក្សា របាយការណ៍សង្ខេបគោលនយោបាយ និងផលិតផលពាក់ព័ន្ធ។ | ប្រចាំឆ្នាំ | | ➢ |
| ប្រភពបន្ទាប់បន្សំ | ព័ត៌មាននិងប្រភពផ្សេងៗ | | ប្រចាំឆ្នាំ | | ➢ |

## ឧបសម្ព័ន្ធ គ.១៖ ការតាមដានសកម្មភាព

យើងកំពុងអនុវត្តប្រព័ន្ធប្រមូលទិន្នន័យដោយប្រើកម្មវិធី Excel ដើម្បីតាមដានសកម្មភាព ឬសកម្មភាពរាយរងធៀបនឹងផែនការការងារ។ ប្រព័ន្ធនេះមានសមត្ថភាពភ្ជាប់ជាមួយប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុរបស់កម្មវិធី ASEAN-ACT។ ប្រព័ន្ធនេះរក្សាទុកព័ត៌មានដើម្បីគាំទ្រផែនការ MEL របស់យើង និងអាចផលិតព័ត៌មានសង្ខេបជាទៀងទាត់។ សកម្មភាពរាយរងត្រូវបានចាត់ប្រភេទជាព្រឹត្តិការណ៍ ឬការចូលរួមដែលទាក់ទងនឹងសិក្ខាសាលា សន្និសីទ សិក្ខាសាលាផ្ទាល់ សិក្ខាសាលាអនឡាញ វគ្គណែនាំ វគ្គសិក្សាអប់រំផ្លូវការ ការបណ្តុះបណ្តាល ការប្រកាសផ្សព្វផ្សាយ ឬកិច្ចប្រជុំ។ កិច្ចប្រជុំដែលនាំឱ្យបង្កើនការកសាងបណ្តាញ កិច្ចសហប្រតិបត្តិការ ការសន្ទនា និងការផ្លាស់ប្តូរព័ត៌មាន ត្រូវបានចាត់ប្រភេទជា 'ព្រឹត្តិការណ៍កិច្ចប្រជុំ'។ ខាងក្រោមនេះជាកម្រងអថេរនៅក្នុងប្រព័ន្ធតាមដានរបស់យើង។ ដោយប្រើប្រាស់ទម្រង់ដូចគ្នាដែលបានប្រើក្នុងដំណាក់កាលទី ២ យើងនឹងអាចភ្ជាប់ និងរួមបញ្ចូលទិន្នន័យដំណាក់កាលទី ១ និងដំណាក់កាលទី ២ ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការពិនិត្យ/វាយតម្លៃនៅចុងកម្មវិធី។

**អថេរ**

- លេខយោង
- ប្រភេទសកម្មភាព (សន្និសីទ កិច្ចប្រជុំ ការចាប់ផ្តើម ការបណ្តុះបណ្តាល សិក្ខាសាលា ការរៀបចំផែនការ ការឆ្លុះបញ្ចាំង/ពិនិត្យឡើងវិញ សិក្ខាសាលាអនឡាញ សិក្ខាសាលាផ្ទាល់ ផ្សេងៗ)
- លេខកូដគម្រោង
- លេខកូដសកម្មភាព
- លេខកូដលទ្ធផលរយៈពេលមធ្យម (មើលទ្រឹស្តីនៃការផ្លាស់ប្តូរក្នុងឧបសម្ព័ន្ធ ១)
- កាលបរិច្ឆេទចាប់ផ្តើមព្រឹត្តិការណ៍
- កាលបរិច្ឆេទបញ្ចប់ព្រឹត្តិការណ៍
- ទីកន្លែង/ទីតាំងនៃព្រឹត្តិការណ៍
- ទីភ្នាក់ងារដៃគូសំខាន់
- គោលបំណងនៃព្រឹត្តិការណ៍
- ការចែករំលែកចំណេះដឹង (មាន/មិនមាន)
- កិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងារ (មាន/មិនមាន)
- ការផ្តោតលើសមភាពយេនឌ័រ (មាន/មិនមាន)
- ការផ្តោតលើសមធម៌ជនពិការ (មាន/មិនមាន)
- ការផ្តោតលើបរិយាបន្នសង្គម (មាន/មិនមាន)

- ការចូលរួមរបស់វិស័យឯកជន (មាន/មិនមាន)
- ការចូលរួមរបស់ជនរងគ្រោះ-ជនដែលធ្លាប់រងគ្រោះ (មាន/មិនមាន)

## ឧបសម្ព័ន្ធខ គ.២ ៖ ព័ត៌មានលម្អិតអំពីអ្នកចូលរួម

មុនព្រឹត្តិការណ៍ និងក្នុងអំឡុងពេលព្រឹត្តិការណ៍ យើងបានស្នើសុំឱ្យអ្នកចូលរួមបំពេញទម្រង់បែបបទចុះឈ្មោះ។ តាមដែលអាចធ្វើទៅបាន ទម្រង់បែបបទចុះឈ្មោះតាមអនឡាញត្រូវបានប្រមូលមុនព្រឹត្តិការណ៍។ នៅថ្ងៃព្រឹត្តិការណ៍ អ្នកចូលរួម បំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទចុះឈ្មោះដើម្បីបញ្ជាក់ការចូលរួមជាក់ស្តែង និងប្រមូលព័ត៌មានសំខាន់ៗ។ យើងកត់ត្រា និងរាប់តែអ្នកចូលរួមជាក់ស្តែងប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលអ្នកដែលបានចុះឈ្មោះជាមុន ប៉ុន្តែមិនបានចូលរួមព្រឹត្តិការណ៍ឡើយ។ អ្នកចូលរួមថ្មីដែលមិនបានចុះឈ្មោះ ប៉ុន្តែបានចូលរួមព្រឹត្តិការណ៍ ក៏ត្រូវបានរាប់បញ្ចូលក្នុងកំណត់ត្រា និងការរាប់អ្នកចូលរួមព្រឹត្តិការណ៍ផងដែរ។

### ទម្រង់បែបបទចុះឈ្មោះ (តាមអនឡាញ ឬជាក្រដាសស្នាម)

- នាមខ្លួន
- នាមត្រកូល
- ភេទ - ប្រុស ស្រី ផ្សេងៗ
- តួនាទី
- ឈ្មោះទីភ្នាក់ងារ
- ទីតាំងរបស់ទីភ្នាក់ងារ
- លេខទូរស័ព្ទ
- អ៊ីមែល
- សំណួរអំពីលទ្ធភាពចូលរួម៖
  ចំណាំ៖ 'សម្របសម្រួលសមស្រប' ក្នុងអំឡុងព្រឹត្តិការណ៍ អាចរួមបញ្ចូលការផ្តល់ទីតាំងរៀបចំព្រឹត្តិការណ៍ដែលបង្កលក្ខណៈងាយស្រួល អ្នកបកប្រែភាសាសញ្ញា ឬឯកសារដែលផ្តល់ឱ្យក្នុងទម្រង់ដែលបង្កភាពងាយស្រួល (ឧ. អក្សរធំៗ ទម្រង់អេឡិចត្រូនិក) តាមការស្នើសុំរបស់អ្នកចូលរួមណាម្នាក់។ តើអ្នកត្រូវការ 'ការសម្របសម្រួលសមស្រប ឬលក្ខខណ្ឌចូលរួម' ផ្សេងទៀតដើម្បីសម្រួលដល់ការចូលរួមពេញលេញរបស់អ្នកក្នុងអំឡុងព្រឹត្តិការណ៍ដែរ ឬទេ? (មាន/មិនមាន/មិនពាក់ព័ន្ធ)
- បើឆ្លើយថា “មាន” សូមជ្រើសរើសការគាំទ្រដែលបង្កភាពងាយស្រួលពីក្នុងជម្រើសដែលមានផ្តល់? (ភាសាសញ្ញាជាតិ ច្បាប់ចម្លងអេឡិចត្រូនិកនៃសម្ភារៈដែលអាចចូលប្រើបានជាមុន សម្ភារៈដែល

មានអក្សរធំៗ ការគាំទ្រដល់អ្នកថែទាំរបស់បុគ្គលដើម្បីចូលរួមព្រឹត្តិការណ៍ ការសម្រួលដល់ការប្រើប្រាស់រទេះរុញ ផ្សេងទៀត សូមបញ្ជាក់)។
បុគ្គលិក ឬអ្នករៀបចំព្រឹត្តិការណ៍ ក៏អាចទាក់ទងទៅអ្នកដើម្បីពិភាក្សា និងរៀបចំផែនការតម្រូវការរបស់អ្នកបន្ថែមទៀតផងដែរ។

- ការយល់ព្រមលើការផ្សព្វផ្សាយ៖ តើអ្នកយល់ព្រមឱ្យថតរូបថតរបស់អ្នកក្នុងអំឡុងព្រឹត្តិការណ៍ដែរឬទេ? (យល់ព្រម/មិនយល់ព្រម)
- កំណត់ចំណាំស្តីពីការយល់ព្រមដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ៖ ប្រសិនបើរំពឹងថាជនរងគ្រោះនឹងចូលរួមក្នុងព្រឹត្តិការណ៍របស់យើង យើងមានទម្រង់បែបបទយល់ព្រមដាច់ដោយឡែកសម្រាប់បំពេញ រួមទាំងព័ត៌មានលម្អិតជាក់លាក់អំពីវិធីសាស្ត្រ។

**ព័ត៌មានលម្អិតអំពីអ្នកចូលរួមព្រឹត្តិការណ៍ (ក្នុង Excel)**

- លេខយោងអ្នកចូលរួម
- លេខយោងសកម្មភាពរង (នៃព្រឹត្តិការណ៍ដែលបានចូលរួម)
- នាមខ្លួន
- នាមត្រកូល
- ភេទ
- តួនាទី
- ទីភ្នាក់ងារ
- ប្រភេទអង្គការ ឬវិស័យ
- ការស្នើសុំការគាំទ្រដើម្បីបង្កលក្ខណៈងាយស្រួល (មាន/មិនមាន/មិនពាក់ព័ន្ធ)
- ប្រភេទនៃការគាំទ្រដើម្បបង្កលក្ខណៈងាយស្រួល
- ការយល់ព្រមលើការផ្សព្វផ្សាយ (យល់ព្រម/មិនយល់ព្រម)
- ការយល់ព្រមដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ដែលបានប្រមូល (មាន/មិនមាន)

## ឧបសម្ព័ន្ធខ គ.៣ ៖ គម្រូទម្រង់សំណួរស្តីពីយោបល់ត្រឡប់ដែលបានស្នើឡើង

យើងប្រមូលយោបល់ត្រឡប់របស់អ្នកចូលរួម បន្ទាប់ពីបញ្ចប់ព្រឹត្តិការណ៍ដែលយើងបានគាំទ្រ ឬធ្វើឡើង។ កម្រងសំណួរស្តីពីយោបល់ត្រឡប់ទូទៅនេះ អាចត្រូវបានប្រើប្រាស់ក្នុងព្រឹត្តិការណ៍ ឬសកម្មភាពណាមួយ (លើកលែងតែកិច្ចប្រជុំ) ដើម្បីប្រមូលមតិ និងយោបល់ត្រឡប់សម្រាប់ការកែលម្អ។ អ្នកចូលរួមព្រឹត្តិការណ៍ ត្រូវបានស្នើឱ្យផ្តល់យោបល់ត្រឡប់ភ្លាមៗបន្ទាប់ពីបញ្ចប់ព្រឹត្តិការណ៍ ឬសកម្មភាព ដោយប្រើប្រាស់ទម្រង់អេឡិចត្រូនិក ឬក្រដាសស្នាម។

ចំណងជើងព្រឹត្តិការណ៍៖

ទីតាំងព្រឹត្តិការណ៍៖

កាលបរិច្ឆេទ៖

១.ភាពរបស់អ្នកចូលរួម ៖ ○ ប្រុស ○ ស្រី ○ ផ្សេងទៀត

២.តើអ្នកធ្វើការឱ្យអ្នកណា? ____________

| **ដោយដាក់ពិន្ទុពី ១ ដល់ ៤ សូមវាយតម្លៃព្រឹត្តិការណ៍ធៀបនឹងអំណះអំណាងខាងក្រោម** | សូមជ្រើសរើសការវាយតម្លៃរបស់អ្នកសម្រាប់អំណះអំណាងនីមួយៗ **១៖ មិនយល់ស្របដាច់ខាត; ២៖ មិនយល់ស្រប; ៣៖ យល់ស្រប; ៤៖ យល់ស្របទាំងស្រុង/យ៉ាងខ្លាំង** | | | |
|---|---|---|---|---|
| | ១ | ២ | ៣ | ៤ |
| ៣.ខ្ញុំបានរៀនសូត្រអ្វីដែលថ្មី (ជំនាញ/ចំណេះដឹង)។ | ○ | ○ | ○ | ○ |
| ៤.ប្រធានបទនេះពាក់ព័ន្ធនឹងការងាររបស់ខ្ញុំ។ | ○ | ○ | ○ | ○ |
| ៥.ព័ត៌មាននេះមានកម្រិតសមស្របអាចឱ្យខ្ញុំយល់បាន។ | ○ | ○ | ○ | ○ |
| ៦.វាគ្មិនមានចំណេះដឹង និងក្បោះក្បាយ។ | ○ | ○ | ○ | ○ |
| ៧.ព្រឹត្តិការណ៍នេះបានផ្តល់ឱកាសដើម្បីពិភាក្សាអំពីបញ្ហាសំខាន់ៗទាក់ទងនឹងអំពើជួញដូរមនុស្ស ឬទាក់ទងនឹងការងាររបស់ខ្ញុំ។ | ○ | ○ | ○ | ○ |
| ៨.ជារួម ខ្ញុំពេញចិត្តនឹងព្រឹត្តិការណ៍នេះ (ការរៀបចំ ការចូលរួម ការរៀនសូត្រ)។ | ○ | ○ | ○ | ○ |

៩.តើអ្នកនឹងវាយតម្លៃដូចម្តេចលើភាពមានប្រយោជន៍ទូទៅនៃព្រឹត្តិការណ៍នេះ?

គ្មានប្រយោជន៍ មានប្រយោជន៍តិចតួច មានប្រយោជន៍ មានប្រយោជន៍ខ្លាំង

១០.តើអ្នកចូលចិត្តអ្វីជាងគេអំពីព្រឹត្តិការណ៍នេះ?

១១.តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនក្នុងអំឡុងព្រឹត្តិការណ៍នេះដោយរបៀបណា?

១២.តើអ្នកមានសំណូមពរអ្វីខ្លះសម្រាប់ការកែលម្អ?

សូមអរគុណសម្រាប់មតិយោបល់របស់អ្នក

## ឧបសម្ព័ន្ធ គ.៤ ៖ ឧទាហរណ៍នៃស្ទង់វាយតម្លៃ និងការស្ទង់មតិក្រុមគោលដៅ

ក្នុងអំឡុងព្រឹត្តិការណ៍សំខាន់ៗ (ឧ. ការពិនិត្យឡើងវិញ និងការឆ្លុះបញ្ចាំង ការផ្ទៀងផ្ទាត់ ឬកិច្ចប្រជុំពិគ្រោះយោបល់) វាអាចជាឱកាសដើម្បីប្រមូលទិន្នន័យតាមដានពីតំណាងដៃគូ។ នេះអាចមានទម្រង់ជាស្ទង់វាយតម្លៃ ការស្ទង់មតិចំគោលដៅ ឬវគ្គជាក្រុម/ការពិភាក្សា។ ព័ត៌មានដែលកើតចេញពីវិធីសាស្ត្រនេះនឹងត្រូវបញ្ចូលទៅក្នុងការរាយការណ៍វឌ្ឍនភាពរបស់យើង និងគាំទ្រលទ្ធផលបែងចែកតាមលទ្ធផលរយៈពេលមធ្យម។

ខាងក្រោមនេះជាឧទាហរណ៍នៃព័ត៌មានដែលត្រូវប្រមូល៖

- ទស្សនៈយល់ឃើញរបស់អ្នកឆ្លើយតបចំពោះ៖
  - ការចូលរួម និងភាពជាដៃគូ
  - កិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងារ
  - ស្ថានភាពនៃការអនុវត្តអនុសញ្ញា ACTIP របស់ពួកគេ និង/ឬការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ
  - ការអនុវត្តវិធីសាស្ត្រ GEDSI
  - ការចែករំលែកចំណេះដឹង
- ទស្សនៈយល់ឃើញរបស់អ្នកឆ្លើយតបចំពោះអត្ថប្រយោជន៍ និងភាពពាក់ព័ន្ធនៃការគាំទ្រដែលបានទទួល
- ទស្សនៈយល់ឃើញរបស់អ្នកឆ្លើយតប ស្តីពីរបៀបដែលពួកគេវាយតម្លៃកិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារ
- ឧទាហរណ៍នៃសមិទ្ធផលរបស់ដៃគូ (អង្គការ) ធៀបនឹងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ឧទាហរណ៍នៃភាពប្រសើរឡើងក្នុងការអនុវត្ត និង/ឬគោលនយោបាយ
- កិច្ចសន្ទនាគោលនយោបាយ និងបទពិសោធន៍រៀនសូត្រ
- សមិទ្ធផលក្នុងការផ្លាស់ប្តូរគោលនយោបាយ និងការអនុវត្តជុំវិញ GEDSI
- បញ្ហាប្រឈម និងមេរៀនដែលបានរៀនសូត្រ។

## ឧបសម្ព័ន្ធ ឃ ៖ គំរូរបាយការណ៍

ឧបសម្ព័ន្ធនេះរៀបរាប់អំពីគំរូរបាយការណ៍ ឬប្លង់របាយការណ៍ដែលបានស្នើឡើង។ ព័ត៌មានលម្អិតនៃគំរូរបាយការណ៍នឹងបញ្ចប់សព្វគ្រប់ នៅពេលដែលក្របខ័ណ្ឌ MERL នេះត្រូវបានបញ្ចប់រួចរាល់។ [បញ្ចូលគំរូរបាយការណ៍នៅទីនេះ]

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួននៃការផ្លាស់ប្តូរគោលនយោបាយ ឬការអនុវត្តដែលត្រូវដាក់បញ្ចូលក្នុងរបាយការណ៍។

### ឧទាហរណ៍នៃការផ្លាស់ប្តូរគោលនយោបាយ និងការអនុវត្ត

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួននៃការផ្លាស់ប្តូរគោលនយោបាយ ឬការអនុវត្តដែលអាចកើតឡើង ៖

- ការបង្កើត និង/ឬការបញ្ចូលគោលការណ៍ណែនាំសម្រាប់តុលាការស្តីពីការគិតគូរដល់ជនរងគ្រោះនៅក្នុងប្រព័ន្ធយុត្តិធម៌
- ការកែលម្អការកំណត់អត្តសញ្ញាណជនរងគ្រោះ
- ការបង្កើត និង/ឬការពង្រឹងយន្តការបញ្ជូនថ្នាក់ជាតិ
- ការកែលម្អគោលនយោបាយ និង/ឬការអនុវត្តក្នុងការជ្រើសរើស និងការជួលឱ្យពលករចំណាកស្រុកធ្វើការ
- ការបង្កើត និង/ឬការអនុវត្តកិច្ចសហប្រតិបត្តិការផ្លូវច្បាប់នៅថ្នាក់តំបន់ស្តីពីបទឧក្រិដ្ឋឆ្លងដែន ជាពិសេសអំពើជួញដូរមនុស្ស
- ការបង្កើត និង/ឬការអនុវត្តក្របខ័ណ្ឌតាមដាន និងរាយការណ៍សម្រាប់វាស់វែងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ការជំរុញចូលរួមរបស់ក្រុមងាយរងគ្រោះ និងជនរងគ្រោះក្នុងកិច្ចសន្ទនាគោលនយោបាយ និងការរៀនសូត្រស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ការជំរុញការចូលរួមរបស់ជនមានពិការភាព ឬអង្គការជនពិការក្នុងកិច្ចសន្ទនាគោលនយោបាយនិងការរៀនសូត្រស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ការចូលរួមជាមួយវិស័យឯកជនក្នុងកិច្ចសន្ទនាគោលនយោបាយ និងការរៀនសូត្រស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងារ ឬអន្តរវិស័យលើកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើជួញដូរមនុស្ស
- ការពង្រឹងការចូលរួមជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងកិច្ចសន្ទនា និងការបង្កើតគោលនយោបាយពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ការពង្រឹង និងស្ថាប័នីយកម្មយន្តការចែករំលែកចំណេះដឹង។

## ឧបសម្ព័ន្ធ ខ ៖ ម៉ាទ្រីសហានិភ័យ

បញ្ចូលតារាងម៉ាទ្រីសហានិភ័យនៅទីនេះ។

## ឧបសម្ព័ន្ធ ច ៖ សកម្មភាព MEL

បញ្ចូលនៅទីនេះ

## ឧបសម្ព័ន្ធ ឆ ៖ ពាក្យគន្លឹះ និងនិយមន័យ

បញ្ចូលនៅទីនេះ